NDI

វិទ្យាស្ថានជាតិ
ប្រជាធិបតេយ្យ
សំរាប់កិច្ចការអន្តរជាតិ







# របាយការណ៍ស្តីពី
# កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត

ខែវិច្ឆិកា ឆ្នាំ២០១១ ដល់  ខែកញ្ញា ឆ្នាំ២០១២

រៀបរៀងដោយ លោកស្រី **ឡូរ៉ា ថនថុន**
នាយកជាន់ខ្ពស់
វិទ្យាស្ថានជាតិប្រជាធិបតេយ្យ
ផ្ទះលេខ៣៥ ផ្លូវលេខ២៤០ កែងផ្លូវលេខ៥៥
សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

**National Democratic Institute**
**455 Massachusetts Avenue, NW, 8th Floor**
**Washington, DC 20001-2621**
**USA**
**Tel: (202) 728 5500**
**Fax: (888) 875 2887**
**www.ndi.org**

រក្សាសិទ្ធិ © វិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ (NDI) ឆ្នាំ២០១២។ រក្សាសិទ្ធិគ្រប់បែបយ៉ាង។ ផ្នែកនៃស្នាដៃនេះ អាចបោះពុម្ពឡើងវិញ និង/ឬបកប្រែក្នុងបំណងមិនធ្វើពាណិជ្ជកម្ម ប្រសិនបើ វិទ្យាស្ថានជាតិ NDI ត្រូវបានទទួលស្គាល់ថា ជាប្រភពដើម ហើយច្បាប់ចម្លងនៃឯកសារនោះ ត្រូវផ្ញើជូនវិទ្យាស្ថានជាតិ NDI ។

របាយការណ៍នេះ ត្រូវបានធ្វើឡើងដោយមានជំនួយសម្បុរសពីពលរដ្ឋអាមេរិក តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ក្រោមកិច្ចព្រមព្រៀងសហប្រតិបត្តិការលេខ ៤៨៦-A-០៩-០០០០។ មតិយោបល់ ដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ គឺជាមតិយោបល់របស់អ្នកនិពន្ធ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ឬរដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ។

# វិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ

វិទ្យាស្ថានជាតិប្រជាធិបតេយ្យ (NDI) គឺជាអង្គការមិនមែនរដ្ឋាភិបាល មិនរកកម្រៃ និងមិនប្រកាន់គណបក្ស ដែលឆ្លើយតបទៅនឹងសេចក្តីប្រាថ្នារបស់ប្រជាពលរដ្ឋនៅជុំវិញពិភពលោក ដែលចង់រស់នៅក្នុងសង្គមប្រជាធិបតេយ្យ មានការទទួលស្គាល់ និងលើកកម្ពស់សិទ្ធិមនុស្សជាមូលដ្ឋាន។

ចាប់តាំងពីការបង្កើតឡើងក្នុងឆ្នាំ១៩៨៣មក វិទ្យាស្ថានជាតិ NDI និងដៃគូក្នុងតំបន់របស់ខ្លួន បានធ្វើការជ្រោមជ្រែង និងពង្រឹងស្ថាប័នប្រជាធិបតេយ្យ និងការអនុវត្តនានា តាមរយៈការពង្រឹងគណបក្សនយោបាយ អង្គការសង្គមស៊ីវិល និងសភា ការការពារដំណើរការបោះឆ្នោត និងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ការបើកចំហរ និងគណនេយ្យភាពនៅក្នុងជួររាជរដ្ឋាភិបាល។

ដោយមានបុគ្គលិក និងអ្នកអនុវត្តន៍នយោបាយស្ម័គ្រចិត្ត មកពីបណ្តាប្រទេសជាង១០០ វិទ្យាស្ថានជាតិ NDI បានអញ្ជើញបុគ្គល និងក្រុមនានាឲ្យមកជួបជុំគ្នា ដើម្បីចែករំលែកមតិយោបល់ ចំណេះដឹង បទពិសោធន៍ និងជំនាញជាមួយគ្នា។ ដៃគូនានាទទួលបទពិសោធន៍ដ៏ទូលំទូលាយពីការអនុវត្តប្រសើរ ក្នុងការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យជាអន្តរជាតិស្របទៅតាមតម្រូវការក្នុងប្រទេសរបស់ខ្លួន។ វិធីសាស្ត្រពហុជាតិរបស់វិទ្យាស្ថានជាតិ NDI ជំរុញគាំទ្រសារមួយ ដែលលើកឡើងថា ទោះបីជាគ្មានគំរូលទ្ធិប្រជាធិបតេយ្យតែមួយក្តី ក៏ប៉ុន្តែ លិទ្ធិប្រជាធិបតេយ្យទាំងអស់ មានគោលការណ៍ស្នូលដ៏ជាក់លាក់។

កិច្ចការរបស់វិទ្យាស្ថាននេះ ប្រកាន់ខ្ជាប់នូវគោលការណ៍ក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ កិច្ចការនេះ ក៏សំដៅលើកស្ទួយការអភិវឌ្ឍប្រព័ន្ធបណ្តាញទំនាក់ទំនងគ្នាជាលក្ខណៈស្ថាប័នក្នុងចំណោមប្រជាពលរដ្ឋ ស្ថាប័ននយោបាយ ក៏ដូចជាមន្ត្រីជាប់ឆ្នោតផងដែរ ហើយនឹងពង្រឹងសមត្ថភាពរបស់ពួកគេ ដើម្បីធ្វើឲ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើង។ សម្រាប់ព័ត៌មានបន្ថែមស្តីពីវិទ្យាស្ថានជាតិ NDI សូមចូលទៅកាន់គេហទំព័រ៖ www.ndi.org ។

# វិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិនៅកម្ពុជា

ចាប់តាំងពីឆ្នាំ១៩៩២មក វិទ្យាស្ថានជាតិNDI បានផ្តល់ជំនួយដល់សកម្មជនប្រជាធិបតេយ្យនៅកម្ពុជា តាមរយៈការសហការជាមួយអង្គការសង្គមស៊ីវិល និងគណបក្សនយោបាយនានា ក៏ដូចជាក្នុងគំនិតផ្តួចផ្តើមគាំទ្រការបោះឆ្នោតផងដែរ។ កម្មវិធីនាពេលបច្ចុប្បន្នរបស់វិទ្យាស្ថាននៅកម្ពុជា មានគោលដៅបង្កើនសមត្ថភាពប្រជាពលរដ្ឋ និងគណបក្សនយោបាយ ក្នុងការចូលរួមឲ្យកាន់តែមានប្រសិទ្ធភាពលើឆាកនយោបាយ។ វិទ្យាស្ថានសហការជាមួយអង្គការសង្គមស៊ីវិលក្នុងតំបន់(ថ្នាក់ខេត្ត)ក្នុងការរៀបចំកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ដែលប្រមូលផ្តុំប្រជាពលរដ្ឋ និងអ្នកតំណាងរាស្ត្រ ធ្វើការពិភាក្សាលើបញ្ហាដែលពាក់ព័ន្ធក្នុងតំបន់។ វិទ្យាស្ថានជាតិ NDI ក៏រៀបចំកិច្ចពិភាក្សាបេក្ខជនតំណាងរាស្ត្រ ការធ្វើសវនកម្មបញ្ជីឈ្មោះអ្នកបោះឆ្នោត ត្រួតពិនិត្យការចុះបញ្ជីឈ្មោះអ្នកបោះឆ្នោត តាមដានការបោះឆ្នោត និងបណ្តុះបណ្តាលគណបក្សនយោបាយ និងបេក្ខជនតំណាងរាស្ត្រផងដែរ។

# បញ្ជីមាតិកា


**១. ប្រវត្តិ** ........ ២

**២. បញ្ហាចម្បងៗ ក្នុងឆ្នាំ២០១២** ........ ៦

ក ជម្លោះដីធ្លី ........ ៧

ខ ការរើសអើង អំពើពុករលួយ និងយុត្តិធម៌ ........ ១១

គ ហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍ ........ ១៤

**៣. លទ្ធផលនៃកិច្ចពិភាក្សាក្រុមគោលដៅ** ........ ១៧

**៤. សកម្មភាព និងលទ្ធផលក្រោយកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត** ........ ២៣

**៥. សេចក្តីសន្និដ្ឋាន** ........ ២៨

**៦. ឧបសម្ព័ន្ធ** ........ ៣៤

## ១. ប្រវត្តិ

នៅប្រទេសកម្ពុជា ទំនាក់ទំនងរវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត មានភាពទន់ខ្សោយ។ ប្រជាពលរដ្ឋ កម្រមានឱកាសក្នុងការបញ្ចេញមតិយោបល់ ឬតស៊ូមតិដើម្បីឲ្យមានកំណែទម្រង់ទៅកាន់អ្នកតំណាងជាប់ឆ្នោតរបស់ខ្លួនណាស់ ហើយសមាជិកសភា(អ្នកតំណាងរាស្ត្រ)ជាច្រើន ក៏មិនសូវចុះសួរសុខទុក្ខម្ចាស់ឆ្នោតរបស់ខ្លួន ដើម្បីរាយការណ៍អំពីសកម្មភាព និងកម្មវិធីរបស់ខ្លួនឲ្យបានទៀងទាត់ផងដែរ។ ទោះបីជាសមាជិកសភាម្នាក់ៗ បានខិតខំប្រឹងប្រែងចុះសួរសុខទុក្ខ និងរៀបចំប្រជុំដោយខ្លួនឯង ឬតាមរយៈគណបក្សនយោបាយរបស់ខ្លួនក៏ដោយ ក៏ប៉ុន្តែ ពួកគេនៅតែប្រឈមនឹងកង្វះពេលវេលា មធ្យោបាយមានកម្រិតនៅថ្នាក់មូលដ្ឋាន និងកង្វះយន្តការប្រកបដោយប្រសិទ្ធភាពដើម្បីធ្វើឲ្យម្ចាស់ឆ្នោតធ្វើការទំនាក់ទំនងជាមួយខ្លួនផងដែរ។ ដោយសារតែការទំនាក់ទំនងនៅមានកម្រិតបែបនេះហើយ ទើបបានជាប្រជាពលរដ្ឋមានការយល់ដឹងតិចតួចអំពីតួនាទីរបស់សភា ឬនីតិប្បញ្ញត្តិ អ្នកតំណាងរាស្ត្រ និងតួនាទីត្រួតពិនិត្យលើការងាររដ្ឋាភិបាល[1]។ សមាជិកសភាជាប់ឆ្នោត មានការយល់ដឹងនៅមានកម្រិតអំពីម្ចាស់ឆ្នោត ហើយសភាជាតិ មិនមានលទ្ធភាពឆ្លើយតបនឹងតម្រូវការ និងផលប្រយោជន៍របស់ម្ចាស់ឆ្នោតខ្លួនឡើយ។

ដើម្បីបើកផ្លូវឲ្យមានទំនាក់ទំនងបែបនេះ វិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ (NDI) បានរៀបចំកិច្ចពិភាក្សាពហុបក្សរវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត (CDs) ចាប់តាំងពីឆ្នាំ២០០៤ ដោយមានការចូលរួមពីតំណាងរាស្ត្រជាប់ឆ្នោតក្នុងរដ្ឋសភា (NA) មកពីគ្រប់បក្សនយោបាយទាំងអស់[2] ។ កិច្ចពិភាក្សានេះ សំដៅលើកកម្ពស់ការយល់ដឹង និងទំនាក់ទំនងរបស់សមាជិកសភាជាមួយម្ចាស់ឆ្នោត និងអប់រំប្រជាពលរដ្ឋអំពីតួនាទី និងទំនួលខុសត្រូវរបស់សមាជិកសភានៅក្នុងសង្គមប្រជាធិបតេយ្យ។ គោលដៅសំខាន់មួយទៀតនៃកម្មវិធីនេះ គឺការបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីជម្រើសផ្នែកនយោបាយរបស់ខ្លួន ដោយសារតែឱកាសក្នុងការយល់ដឹងរបស់ខ្លួនអំពីទស្សនៈ និងគោលនយោបាយផ្សេងៗទៀតពីគណបក្សមិនកាន់អំណាចនៅមានកម្រិត។ កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត (CD) សំដៅធ្វើប្រក្រតីកម្ម និងបង្ហាញពីសារៈសំខាន់នៃកិច្ចពិភាក្សានៅកម្ពុជា ដែលកិច្ចពិភាក្សាផ្លាស់ប្តូរយោបល់ពីគោលនយោបាយរវាងគូបដិបក្ខនយោបាយកម្រនឹងកើតឡើងណាស់ ហើយក៏ត្រូវបានពិចារណាដោយប្រុងប្រយ័ត្នផងដែរ ។

ពីខែវិច្ឆិកា ឆ្នាំ២០១១ ដល់ខែកញ្ញា ឆ្នាំ២០១២ វិទ្យាស្ថានជាតិ NDI បានរៀបចំកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតចំនួន១៤ ក្នុងខេត្តចំនួន៨ នៅកម្ពុជា រួមមាន ខេត្តបាត់ដំបង

[1] តាមការស្ទង់មតិរបស់វិទ្យាស្ថានជាតិ NDI នៅខេត្តចំនួនបី រួមមាន ខេត្តក្រចេះ ខេត្តកំពង់ចាម និងខេត្តកំពង់ឆ្នាំង បានឲ្យដឹងថា ប្រជាពលរដ្ឋចំនួន២១,៨% មិនធ្លាប់ដែលលឺពាក្យ រដ្ឋសភា នោះទេ ហើយ៥៣,១% និយាយថា ទោះបីជាពួកគេធ្លាប់លឺពាក្យនេះក្តី ក៏ប៉ុន្តែពួកគេ មិនយល់ពីអត្ថន័យរបស់ពាក្យនេះឡើយ។ លើសពីនេះ ប្រជាជនចំនួន៤៨,១% មិនធ្លាប់លឺពាក្យ "សមាជិករដ្ឋសភា" នេះទាល់តែសោះ។

[2] ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) បានផ្តល់ជំនួយជាថវិកាក្នុងកិច្ចពិភាក្សានេះ ចាប់តាំងពីពេលកកើតដំបូងមកម្ល៉េះ។ នៅខែតុលា ឆ្នាំ២០០៩ កម្មវិធីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ត្រូវបានរាប់បញ្ចូលទៅក្នុងកម្មវិធីរយៈពេលប្រាំឆ្នាំនៅកម្ពុជា ក្រោមជំនួយពី USAID ហៅថាកម្មវិធីគណនេយ្យភាពនៅក្នុងអភិបាលកិច្ច និងនយោបាយ (AGAP)។

ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ខេត្តក្រចេះ ខេត្តកំពង់ធំ និងខេត្តសៀមរាប។ ខេត្តទាំងអស់ ត្រូវបានជ្រើសរើសដោយផ្អែកលើតំណាងពហុបក្ស[3]របស់ខ្លួនដែលមានអាសនៈក្នុងរដ្ឋសភា ដែលគណបក្សនយោបាយពីរ ឬច្រើន មានសមាជិកសភាមកពីគណបក្សដែលបានជាប់ឆ្នោតក្នុងខេត្តនោះ។ សមាជិកសភាចំនួន២៥រូបតំណាងឲ្យខេត្តទាំងនេះ មកពីគណបក្សចំនួនបួន រួមមាន គណបក្សប្រជាជនកម្ពុជា (CPP) គណបក្ស សម រង្ស៊ី (SRP) គណបក្សសិទ្ធិមនុស្ស (HRP) និងគណបក្សនរោត្តមរណឫទ្ធិ (NRP) បានចូលរួមនៅក្នុងកិច្ចពិភាក្សានេះ[4]។ កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ត្រូវបានប្រារព្ធធ្វើឡើងចំនួនបីលើក នៅខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង និងខេត្តក្រចេះ ដោយមួយលើកៗ ធ្វើឡើងនៅឃុំខុសៗគ្នា ហើយមួយលើកទៀត ធ្វើឡើងនៅខេត្តដទៃទៀត។

| ខេត្ត | គណបក្សដែលចូលរួមក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត | | | |
|---|---|---|---|---|
| បាត់ដំបង | CPP | SRP | | |
| កំពង់ចាម (x៣) | CPP | SRP | HRP | NRP |
| កំពង់ឆ្នាំង (x៣) | CPP | SRP | | |
| កំពង់ស្ពឺ | CPP | SRP | | |
| កណ្តាល | CPP | SRP | HRP | |
| ក្រចេះ (x៣) | CPP | SRP | | |
| សៀមរាប | CPP | SRP | | |

កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត មានទម្រង់ស្រដៀងគ្នាទៅនឹងកិច្ចប្រជុំសាធារណៈរបស់សាលាក្រុង (town hall meeting) ផងដែរ ហើយគ្រប់មជ្ឈដ្ឋានទាំងអស់ ត្រូវបានស្វាគមន៍ឲ្យចូលរួម។ ប្រជាពលរដ្ឋនៅតាមសហគមន៍ចន្លោះពី២៥០នាក់ ទៅ១.០០០នាក់ បានចូលរួមនៅក្នុងព្រឹត្តិការណ៍នីមួយៗ ដែលត្រូវបានសម្របសម្រួលដោយបុគ្គលិកដែលមានបទពិសោធន៍នៃវិទ្យាស្ថានជាតិ NDI ។ សមាជិកសភាមកពីគណបក្សផ្សេងៗគ្នា ដែលតំណាងឲ្យខេត្តនីមួយៗ ត្រូវបានអញ្ជើញឲ្យចូលអង្គុយនៅតុខាងមុខអ្នកចូលរួម និងថ្លែងសុន្ទរកថាបើកកិច្ចប្រជុំទៅកាន់អ្នកចូលរួម។ កិច្ចពិភាក្សានេះ បើកឱកាសឲ្យអ្នកចូលរួមបង្ហាញពីក្តីកង្វល់របស់ពួកគេលើកសំណួរដោយផ្ទាល់ទៅកាន់អ្នកតំណាងរាស្ត្រ ហើយស្នើសុំឲ្យមានការចាត់វិធានការដោះស្រាយបញ្ហានានា។ ក្នុងអំឡុងពេលឆ្លើយតបដែលផ្តល់ឲ្យ អ្នកតំណាងរាស្ត្រឆ្លៀតឱកាសផ្តល់ព័ត៌មានឲ្យប្រជាពលរដ្ឋយល់ដឹងអំពីសកម្មភាពរបស់អង្គនីតិប្បញ្ញត្តិ និងរាជរដ្ឋាភិបាល ហើយផ្តល់

[3] មណ្ឌលបោះឆ្នោតនៅតាមបណ្តាខេត្តក្នុងប្រទេសកម្ពុជា មានសមាជិកចាប់ពី១នាក់ ទៅ១៨នាក់ អាស្រ័យលើចំនួនប្រជាជន។ វិទ្យាស្ថានជាតិ NDI បានរៀបចំកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនេះឡើងនៅតាមបណ្តាខេត្តទាំងឡាយណា ដែលអ្នកតំណាងរាស្ត្រមកពី គណបក្សចំនួនពីរ ឬច្រើន ត្រូវបានបោះឆ្នោតឲ្យ។

[4] ចាប់ពីឆ្នាំ២០០៤ ដល់ខែមីនា ឆ្នាំ២០០៨ មានតែគណបក្សនយោបាយចំនួនបីប៉ុណ្ណោះ រួមមាន គណបក្សប្រជាជនកម្ពុជា (CPP) គណបក្ស សម រង្ស៊ី (SRP) និងគណបក្សហ្វ៊ុនស៊ិនប៉ិច (FUNCINPEC) ដែលបានទទួលអាសនៈនៅក្នុងរដ្ឋសភា។ ដោយសារមានគណបក្សថ្មីចំនួនពីរ រួមមាន គណបក្សសិទ្ធិមនុស្ស (HRP) និងគណបក្សនរោត្តមរណឫទ្ធិ (NRP) បានទទួលអាសនៈក្នុងការបោះឆ្នោតក្នុងឆ្នាំ២០០៨នោះ បច្ចុប្បន្ន គណបក្សចំនួនប្រាំ បានចូលរួមនៅក្នុងកិច្ចពិភាក្សានេះ។

ព័ត៌មានផ្សេងៗទៀតដែលពាក់ព័ន្ធនឹងម្ចាស់ឆ្នោតរបស់ពួកគេ។ កិច្ចពិភាក្សានេះ លើកទឹកចិត្តឲ្យមានការពិភាក្សាទៅវិញទៅមក ដោយគ្មានការគ្រោងទុក ហើយអនុញ្ញាតឲ្យប្រជាពលរដ្ឋសួរសំណួរដេញដោល និងបង្ហាញពីតម្រូវការរបស់ពួកគេ។ វេទិកានេះ ផ្តល់នូវឱកាសដ៏កម្រមួយសម្រាប់កិច្ចពិភាក្សាដេញដោលពីគោលនយោបាយ ហើយដោះស្រាយភាពខុសគ្នារវាងសមាជិកសភាមកពីគណបក្សខុសៗគ្នា និងដំណោះស្រាយរបស់ពួកគេ ចំពោះក្តីកង្វល់ជាតិ និងក្នុងមូលដ្ឋាន។

ដើម្បីធានាបាននូវសមធម៌ និងអព្យាក្រឹតភាព និងដើម្បីបើកកិច្ចពិភាក្សាដ៏មានសារៈសំខាន់នេះ វិទ្យាស្ថានជាតិ NDI បានបង្កើតក្រមសីលធម៌មួយ[5]សម្រាប់អ្នកតំណាងរាស្ត្រជាវាគ្មិនអ្នកចូលរួម និងអ្នកសម្របសម្រួលរបស់វិទ្យាស្ថានជាតិ NDI ។ ក្រមសីលធម៌នេះ កំណត់យ៉ាងច្បាស់លាស់ទៅលើផ្នែកមួយចំនួន ដូចជា ការបែងចែកពេលវេលាសម្រាប់ការធ្វើអត្ថាធិប្បាយប្រធានបទដែលមានភាពសមរម្យ និងមិនសមរម្យសំរាប់កិច្ចពិភាក្សា ក៏ដូចជាវិន័យនានាដែលពាក់ព័ន្ធនឹងការចូលរួមរបស់អ្នកស្តាប់ផងដែរ។ អាជ្ញាធរមូលដ្ឋាន ដូចជា ក្រុមប្រឹក្សាឃុំ ប្រធានភូមិ និងមន្ត្រីស្រុក និងខេត្ត ជារឿយៗ មានវត្តមានក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ហើយនៅឆ្នាំ២០១០ ដោយមានការស្នើសុំពីគណបក្សនានា វិទ្យាស្ថានជាតិ NDI ក៏បានចាប់ផ្តើមផ្តល់ពេលវេលាឲ្យអាជ្ញាធរមូលដ្ឋាន ដើម្បីឡើងបកស្រាយបន្ថែមលើកង្វល់ និងបញ្ហាដែលបានលើកឡើងដោយអ្នកចូលរួម នៅចុងបញ្ចប់នៃកិច្ចពិភាក្សា។ ស្ថានីយ៍វិទ្យុចំនួនពីរ រួមមានវិទ្យុអង្គរវដ្តផ្សាយតាមវិទ្យុសារិកា FM៩៥.៥ ខេត្តសៀមរាប និងវិទ្យុមហានគរ FM៩៣.៥ នៅរាជធានីភ្នំពេញ បានផ្សព្វផ្សាយកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ទៅដល់ខេត្តក្រុងចំនួន២០ ក្នុងចំណោមខេត្តក្រុងចំនួន២៤[6] ដោយពង្រីកវិសាលភាពនៃកម្មវិធីនេះ តាមរយៈការធានាឲ្យមានអ្នកស្តាប់កាន់តែច្រើនឡើង។

វិទ្យាស្ថានជាតិ NDI ធ្វើការជាមួយអង្គការសង្គមស៊ីវិល (CSOs) ដែលមានមូលដ្ឋានក្នុងតំបន់ ឬអ្នកស្ម័គ្រចិត្តសហគមន៍នៅក្នុងខេត្តនីមួយៗ ដែលមានការរៀបចំកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត[7]។ អង្គការសង្គមស៊ីវិលទាំងនេះ ដើរតួនាទីយ៉ាងសំខាន់ក្នុងការ

---

[5] កាលពីឆ្នាំ២០០៨ វិទ្យាស្ថានជាតិ NDI បានបង្កើតក្រមសីលធម៌ ដើម្បីធ្វើឲ្យជ្រះស្រឡះរាល់ការយល់ខុសទាំងឡាយ និងចៀសវាងពីការភ័ន្តច្រឡំអំពីដំណើរការរបស់កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ក៏ដូចជាការចោទប្រកាន់ពីភាពលម្អៀងនានា។ វិទ្យាស្ថានជាតិ NDI ក៏ធ្វើការហាមប្រាមការវាយប្រហារពាក្យសម្តី និងការប្រមាថមាក់ងាយជាលក្ខណៈបុគ្គលក្នុងអំឡុងពេលកិច្ចពិភាក្សានេះផងដែរ។ វិធីសាស្ត្រទប់ស្កាត់ និងដោះស្រាយជម្លោះនេះ បានទទួលការឯកភាពគ្នាពីគណបក្សនយោបាយចំនួនប្រាំដែលជាតំណាងនៅក្នុងកម្មវិធីនេះ។ វិទ្យាស្ថានជាតិ NDI ត្រួតពិនិត្យឡើងវិញនូវក្រមសីលធម៌នេះ ជាមួយគណបក្សទាំងអស់ដើម្បីធានានូវភាពជាប់ពាក់ព័ន្ធ និងកែប្រែក្នុងករណីចាំបាច់។

[6] ខេត្តដែលត្រូវរាប់បញ្ចូលរួមមាន៖ ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ ខេត្តពោធិសាត់ ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តក្រចេះ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកែប ខេត្តតាកែវ ខេត្តកំពត ខេត្តកោះកុង ខេត្តប៉ៃលិន ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ និងរាជធានីភ្នំពេញ។

[7] ចាប់ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១២ អង្គការសង្គមស៊ីវិលដែលជាដៃគូរបស់វិទ្យាស្ថានជាតិ NDI រួមមាន៖ សមាគមឥន្ទ្រទេវី (IDA) នៅខេត្តកណ្តាល អង្គការនគរភ្នំពង្រឹងសុខុមាលភាពសហគមន៍ (NPCEO) នៅខេត្តកំពង់ចាម អង្គការកាត់បន្ថយទុពលភាពនិងអនក្ខរភាព (VIR) នៅខេត្តសៀមរាប អង្គការក្រុមទ្រទ្រង់ភូមិ (VSG) នៅខេត្តបាត់ដំបង អង្គការបង្កើនសមត្ថភាពសហគមន៍ដើម្បីអភិវឌ្ឍន៍ (CCD)

រៀបចំផែនការ និងអនុវត្តកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រនិងម្ចាស់ឆ្នោត ក៏ដូចជា តាមដានផលប៉ះពាល់នៃកិច្ចពិភាក្សានេះនៅក្នុងតំបន់។ ដៃគូនៅតាមបណ្តាខេត្ត ជាអ្នកកំណត់ភូមិដែលនឹងត្រូវរៀបចំកិច្ចពិភាក្សានេះ ធ្វើការទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន និងចាត់ចែងការរៀបចំព្រឹត្តិការណ៍នេះឡើង។ លើសពីនេះ វិទ្យាស្ថានជាតិ NDI មានអ្នកស្ម័គ្រចិត្ត (CVs) នៅក្នុងសហគមន៍នៃខេត្តនីមួយៗ ដែលជួយកៀងគរប្រជាពលរដ្ឋមុនពេលបើកកិច្ចពិភាក្សា។ ពីរសប្តាហ៍មុនពេលរៀបចំកិច្ចពិភាក្សានីមួយៗ អ្នកស្ម័គ្រចិត្តសហគមន៍ និងអង្គការដៃគូថ្នាក់ខេត្ត បានបើកកិច្ចពិភាក្សាក្រុមតូច ដោយមានការចូលរួមពីប្រជាពលរដ្ឋប្រហែល៣៥នាក់ ដើម្បីទទួលបានព័ត៌មានអំពីបញ្ហាប្រឈមរបស់សហគមន៍។ បន្ទាប់មកទៀត វិទ្យាស្ថានជាតិ NDI ធ្វើការសង្ខេបជូនអ្នកតំណាងរាស្ត្រដែលនឹងចូលរួមកម្មវិធីអំពីបញ្ហាទាំងនេះ ដើម្បីរៀបចំដាក់នៅក្នុងកិច្ចពិភាក្សា។ លើសពីនេះ ក្រុមការងាររបស់វិទ្យាស្ថានជាតិ NDI ធ្វើដំណើរទៅកាន់ទីតាំងដែលនឹងបើកកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ពីរបីថ្ងៃមុនពេលធ្វើវេទិកា ដើម្បីបង្ហាញពីគោលបំណងនៃកម្មវិធីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ទៅកាន់អាជ្ញាធរមូលដ្ឋាន និងក្រុមសហគមន៍ និងធានាឲ្យមានការជួយជ្រោមជ្រែងរបស់ពួកគេ។ អំឡុងពេលនៃកិច្ចពិភាក្សានេះ បុគ្គលិកនៃវិទ្យាស្ថានជាតិ NDI ពណ៌នាអំពីកម្មវត្ថុនៃកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត សារៈសំខាន់នៃការរៀបចំកិច្ចពិភាក្សាពហុបក្សគោលគំនិតស្តីពីគណនេយ្យភាព និងមុខងារតំណាងនៃសមាជិកសភា។ មន្ត្រីមូលដ្ឋាន មានឱកាសសួរសំណួរ និងចែករំលែកនូវក្តីបារម្ភរបស់ពួកគេទាក់ទិននឹងព្រឹត្តិការណ៍នេះ។




ឯកឧត្តម លី សុន អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា និង ឯកឧត្តម សុខ អ៊ុំស៊ា អ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី នៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត នៅភូមិក្រាំងបឹង ឃុំតាំងសំរោង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១២

នៅខេត្តកំពង់ឆ្នាំង និងអង្គការសកម្មភាពដើម្បីសុខុមាលភាពស្ត្រីកម្ពុជា (KWWA) នៅខេត្តក្រចេះ។ វិទ្យាស្ថានជាតិ NDI បានធ្វើការជាមួយអ្នកស្ម័គ្រចិត្តខេត្តកំពង់ស្ពឺតែមួយគត់។

ក្រោយការបញ្ចប់កិច្ចពិភាក្សានីមួយៗ វិទ្យាស្ថានជាតិ NDI បង្កើតតារាងតាមដានមួយ ដែលគូសបញ្ជាក់ពីបញ្ហាដែលបានលើកឡើង និងសកម្មភាពដែលបានស្នើឡើងដោយអ្នកតំណាងរាស្ត្រនីមួយៗ។ បន្ទាប់មក វិទ្យាស្ថានជាតិ NDI ធ្វើការទាក់ទងជាមួយនឹងអ្នកតំណាងរាស្ត្រយ៉ាងទៀតទាត់ ដើម្បីតាមដានការវិវឌ្ឍនៃការគោរពតាមពាក្យសន្យារបស់ពួកគេ ក្នុងអំឡុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ ស្របជាមួយគ្នានេះដែរ អង្គការដៃគូថ្នាក់មូលដ្ឋានរបស់វិទ្យាស្ថានជាតិ NDI បានចុះដោយផ្ទាល់ទៅកាន់ភូមិនានា ដែលរៀបចំកិច្ចពិភាក្សានេះ ដើម្បីតាមដានការផ្លាស់ប្តូរដែលជាលទ្ធផលនៃកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ លទ្ធផល និងគំនិតផ្តួចផ្តើមទាំងអស់ ត្រូវបានកត់ត្រាទុក និងរាយការណ៍ត្រឡប់ទៅកាន់សហគមន៍វិញ។ ការតាមដាននេះ មានសារៈសំខាន់ក្នុងការលើកកម្ពស់ឲ្យមានគណនេយ្យភាព តាមរយៈការផ្តល់ឲ្យប្រជាពលរដ្ឋនូវព័ត៌មានដែលត្រូវការ ដើម្បីវាយតម្លៃការអនុវត្តរបស់តំណាងរបស់ពួកគេ។ វិទ្យាស្ថានជាតិ NDI ក៏បានរៀបចំកិច្ចពិភាក្សាក្រុមគោលដៅ មុននិងក្រោយកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រនិងម្ចាស់ឆ្នោត ដើម្បីប្រមូលព័ត៌មានដែលមានគុណភាព និងវាយតម្លៃពីឥទ្ធិពលនៃកម្មវិធីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនេះ ដោយផ្តោតសំខាន់ទៅលើចំណេះដឹង អាកប្បកិរិយា និងទម្លាប់អនុវត្តន៍របស់ប្រជាពលរដ្ឋ។ វិទ្យាស្ថានជាតិ NDI ក៏ធ្វើការសម្ភាសន៍ជាមួយមន្ត្រីមូលដ្ឋានផងដែរ ក្រោយពីមានកិច្ចពិភាក្សាតំណាងរាស្ត្រ និងម្ចាស់ឆ្នោតរួចមក ដើម្បីប្រមែប្រមូលព័ត៌មាន និងទស្សនវិស័យរបស់ពួកគេ អំពីកិច្ចពិភាក្សា និងចំណេះដឹងដែលទទួលបាន។

កម្មវិធីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រនិងម្ចាស់ឆ្នោត បានជំរុញឲ្យមានការយល់ដឹង ក្នុងចំណោមសាធារណជនកម្ពុជា អំពីទំនាក់ទំនងរវាងបញ្ហាក្នុងតំបន់ និងទំនួលខុសត្រូវរបស់មន្ត្រីជាប់ឆ្នោត។ កិច្ចពិភាក្សានេះ ផ្តល់ឱកាសដល់អ្នកតំណាងរាស្ត្រ ដើម្បីពង្រឹងទំនាក់ទំនងល្អបន្ថែមទៀតជាមួយម្ចាស់ឆ្នោត ក៏ដូចជាធ្វើការឆ្លើយតបចំពោះសំណូមពរ និងតម្រូវការរបស់សាធារណជន។ លើសពីនេះ តាមរយៈការដោះស្រាយភាពខុសប្លែកគ្នារវាងគណបក្សនយោបាយនានា ប្រជាពលរដ្ឋមានឱកាសដើម្បីសិក្សារៀនសូត្របន្ថែមទៀត អំពីមតិយោបល់ខុសៗគ្នារបស់អ្នកតំណាងរាស្ត្រ ការភ្ជាប់ទំនាក់ទំនង និងកម្មវិធីនយោបាយរបស់គណបក្ស ហើយថែមទាំងយល់ដឹងពីជម្រើសនយោបាយរបស់ពួកគេផងដែរ។ ក្នុងករណីជាច្រើន កិច្ចពិភាក្សារវាងអ្នកតំណាង-រាស្ត្រនិងម្ចាស់ឆ្នោត បានញុំាងឲ្យមានការចាត់វិធានការជាក់ស្តែងពីសំណាក់អ្នកតំណាងរាស្ត្រដែលចូលរួម ដែលមានឥទ្ធិពលដោយផ្ទាល់ទៅលើសហគមន៍ទទួលបន្ទុករបស់ខ្លួន ក្នុងនោះរួមមាន ដំណោះស្រាយជម្លោះដីធ្លី និងការបំពេញតម្រូវការហេដ្ឋារចនាសម្ព័ន្ធ និងកសិកម្ម។

## ២. បញ្ហាចម្បងៗ ក្នុងឆ្នាំ២០១២[8]

[8] ការបញ្ចេញមតិយោបល់របស់អ្នកចូលរួម និងអ្នកតំណាងរាស្ត្រ ក្នុងអំឡុងពេលនៃកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់វិទ្យាស្ថានជាតិ NDI ឡើយ។ "បញ្ហាចម្បងៗ" ទាំងនេះ តំណាងឲ្យបញ្ហា ដែលត្រូវអ្នកចូលរួមក្នុងកិច្ចពិភាក្សានេះ លើកឡើង ជាញឹកញាប់ ហើយរបាយការណ៍នេះ គឺសំដៅសង្ខេបពាក្យសំដី ក្តីកង្វល់ និងចំណាប់អារម្មណ៍របស់ពួកគាត់។ របាយការណ៍ទាំងស្រុងនៃកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតជាភាសាអង់គ្លេស អាចរកបានតាមការស្នើសុំ។

កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតចំនួន១៤ ដែលត្រូវបានរៀបចំឡើងចាប់ពីខែវិច្ឆិកា ឆ្នាំ២០១១ ដល់ខែកញ្ញា ឆ្នាំ២០១២ បានទទួលការចូលរួមពីប្រជាជនជាង៧.៥០០នាក់ ក្នុងនោះ៤២% គឺជាស្ត្រី និងអ្នកតំណាងរាស្ត្រចំនួន២៥រូប (ក្នុងនោះមានស្ត្រីបីនាក់)។ នៅខេត្តទាំងប្រាំបី អ្នកចូលរួមក្នុងកិច្ចពិភាក្សានេះ បានលើកឡើងពីបញ្ហាដូចៗគ្នាចំនួនបី ដែលធ្វើឲ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ខ្លួនជាទីបំផុត ទី១ គឺជម្លោះដីធ្លី ទី២ គឺការរើសអើង អំពើពុករលួយ និងការអនុវត្តច្បាប់ប្រកបដោយភាពលម្អៀងពីសំណាក់អាជ្ញាធរមូលដ្ឋាន និងទី៣ គឺតម្រូវការហេដ្ឋារចនា-សម្ព័ន្ធ និងការអភិវឌ្ឍ។ វិសមភាព គឺជាមូលហេតុចម្បងនៃបញ្ហាទាំងនេះ ហើយ អ្នកចូលរួម បានសម្តែងក្តីកង្វល់របស់ខ្លួនថា អ្នកមាន និងអ្នកមានអំណាច ទើបជាអ្នកទទួលបានផលប្រយោជន៍គ្រប់យ៉ាង គឺទាំងដីធ្លី ការអភិវឌ្ឍ និងយុត្តិធម៌។ នៅខេត្តទាំងនេះ ប្រជាពលរដ្ឋក៏បានឲ្យដឹងផងដែរថា ទឹកប្រាក់មានឥទ្ធិពលគ្របដណ្តប់លើជីវិតមនុស្សគ្រប់ទិដ្ឋភាពទាំងអស់ ហើយពួកគេមានអារម្មណ៍ថា ខ្លួនកំពុងបាត់បង់ទឹកដីទៅក្នុងដៃក្រុមហ៊ុនបរទេស និងក្រុមហ៊ុនឯកជន។ អ្នកចូលរួមម្នាក់បានលើកឡើងថា "បញ្ហាអ្នកមាន និងបញ្ហាអ្នកក្រខុសគ្នាត្រង់ថា បញ្ហាអ្នកក្រ កម្រនឹងត្រូវបានដោះស្រាយណាស់"។

### ក. ជម្លោះដីធ្លី

បញ្ហាដីធ្លី គឺជាកង្វល់ធំបំផុតដែលប្រជាពលរដ្ឋបានលើកយកមកពិភាក្សាជាញឹកញាប់ ហើយចំនួនវិវាទដីធ្លីនេះទៀតសោតមានចំនួនច្រើនជាងកាលពីបណ្តាឆ្នាំមុនៗ ដែលមានការរៀបចំកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតទៅទៀត។ អំឡុងកិច្ចពិភាក្សានីមួយៗ អ្នកចូលរួមតែងបានរៀបរាប់ពីការរឹបអូសយកដីធ្លីរបស់ខ្លួន ឬរបស់ប្រជាជនដទៃទៀតក្នុងសហគមន៍ខ្លួនពីសំណាក់ក្រុមហ៊ុន ឬតាមរយៈគោលនយោបាយផ្តល់ដីសម្បទាន។ ក្នុងកិច្ចពិភាក្សាខ្លះ បញ្ហាផ្សេងៗទៀត ត្រូវបានលើកយកមកពិភាក្សាតិចតួចបំផុត។ ប្រជាពលរដ្ឋជាច្រើន ដែលលើកយកបញ្ហានេះមកពិភាក្សា បានរៀបរាប់អំពីកត្តាប្រឈមក្នុងការការពារអចលនទ្រព្យរបស់ខ្លួន ហើយជារឿយៗ ពួកគាត់បានរាយការណ៍អំពីការព្រងើយកន្តើយរបស់អាជ្ញាធរមូលដ្ឋានចំពោះការដោះស្រាយបញ្ហារបស់ពួកគាត់។ ឧទាហរណ៍ ប្រជាពលរដ្ឋ បានធ្វើដំណើរយ៉ាងឆ្ងាយដើម្បីទៅប្រាប់អ្នកតំណាងរាស្ត្រអំពីបញ្ហារបស់ខ្លួន ដោយសារតែអាជ្ញាធរ និងតុលាការនៅក្នុងសហគមន៍របស់ពួកគេ មិនបានជួយដោះស្រាយបញ្ហាទាំងនេះបាន។

---

*នៅខេត្តក្រចេះ ស្ត្រីម្នាក់ បានធ្វើដំណើរ៧០គីឡូម៉ែត្រ ដើម្បីមកចូលរួមកម្មវិធីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ត្អូញត្អែរពីការផ្តល់ដីសម្បទានទៅឲ្យក្រុមហ៊ុនវៀតណាម ដាយណាម ដែលបណ្តេញគ្រួសារជាច្រើនចេញពីដីរបស់ពួកគេ។ ស្ត្រីរូបនោះ ក៏បានដាក់លិខិតរួមមួយដោយភ្ជាប់ជាមួយស្នាមមេដៃជូនទៅអ្នកតំណាងរាស្ត្រក្នុងកំឡុងពេលធ្វើវេទិកា។ គាត់បានទាក់ទងជាមួយអាជ្ញាធរមូលដ្ឋាន ប៉ុន្តែគ្មានដំណោះស្រាយទេ។*

---

អ្នកចូលរួមក្នុងកិច្ចពិភាក្សានេះ បានរិះគន់គោលនយោបាយផ្តល់ដីសម្បទានរបស់រាជរដ្ឋាភិបាល ហើយបានត្អូញត្អែរពីអំពើពុករលួយរបស់អាជ្ញាធរមូលដ្ឋាន និងតុលាការពាក់ព័ន្ធនឹងករណីដីធ្លី និងអំពីនីតិវិធីចេញប័ណ្ណកម្មសិទ្ធិដីធ្លីប្រកបដោយភាពយឺតយ៉ាវ និងពុករលួយ។ ជម្លោះដីធ្លី ដែលត្រូវបានលើកឡើង ជាធម្មតា ពាក់ព័ន្ធនឹងក្រុមគ្រួសារដែលត្រូវបានបណ្តេញចេញពីដីរបស់ខ្លួន ដោយសារតែដីនោះត្រូវបានផ្តល់ជាសម្បទានឲ្យក្រុមហ៊ុនឯកជនរួចទៅហើយ។ អ្នកចូលរួម បានចោទជាសំណួរអំពីគោលនយោបាយផ្តល់ដីសម្បទាននេះ ដោយទាមទារឲ្យមានការពន្យល់ពីហេតុផលដែលក្រុមហ៊ុននានា (ភាគច្រើនជាក្រុមហ៊ុនបរទេស) ទទួលបានការយកចិត្តទុកដាក់ជាងប្រជាពលរដ្ឋ។ ពួកគេក៏បានរិះគន់ថា ក្រុមហ៊ុននានាចំណាយប្រាក់តែបន្តិចបន្តួចប៉ុណ្ណោះ ដើម្បីទទួលបានដីសម្បទាន ហើយពួកគាត់ បានសម្តែងពីបំណងប្រាថ្នាក្នុងការយកដីរបស់ខ្លួនមកវិញ តាមរយៈការបង់ប្រាក់ក្នុងចំនួនដូចគ្នា។ ពួកគេក៏បានច្រានចោលការលើកឡើងដែលថា ការផ្តល់ដីសម្បទាននេះ នាំមកនូវឱកាសការងារជូនប្រជាជនកម្ពុជា ដោយបានលើកឡើងថា ជារឿយៗ ក្រុមហ៊ុនបានរើសកម្មករថ្មីៗជាជនបរទេស ឬបើមិនដូច្នេះទេ ដីទាំងនោះត្រូវបានកាប់ឆ្ការអស់ ហើយទុកឲ្យនៅទំនេរតែម្តង។

*នៅខេត្តក្រចេះ បុរសម្នាក់ បានត្អូញត្អែរយ៉ាងខ្លាំងអំពីគោលនយោបាយផ្តល់ដីសម្បទានរបស់រាជរដ្ឋាភិបាល។ លោក បានស្នើសុំភស្តុតាងដែលបញ្ជាក់ថា រាជរដ្ឋាភិបាលពិតជាកំពុងអភិវឌ្ឍន៍ប្រទេសជាតិ ដូចដែលបានអះអាងមែន។ លោកបានចោទសួរថា "ដោយសារតែប្រជាពលរដ្ឋដល់ទៅ៨៥% គឺជាកសិករ តើការអភិវឌ្ឍអាចធ្វើឡើងតាមរបៀបណាតាមរយៈការជួលដីសម្បទានរយៈពេល៩៩ឆ្នាំឬ?"*

*អ្នកចូលរួមខាងលើនេះ បានស្នើឲ្យអ្នកស្តាប់ទាំងអស់ទះដៃ ប្រសិនបើពួកគេយល់ស្រប ហើយលោកក៏បានទទួលស្នូរទះដៃយ៉ាងកងរំពង។ លោកបានលើកជាសំណួរចុងក្រោយថា តើកូនៗរបស់ខ្លួននឹងប្រកបមុខរបរអ្វីនាពេលអនាគត នៅពេលដែលគ្មានដីដូច្នេះ?*

នៅក្នុងករណីជាច្រើន គ្រួសារមួយចំនួនអះអាងថា ខ្លួនមានប័ណ្ណកម្មសិទ្ធិដីធ្លីស្របច្បាប់រួចហើយ ប៉ុន្តែបែរជាត្រូវបានបណ្តេញចេញពីដីរបស់ខ្លួន ពីសំណាក់អ្នកមានអំណាច ដោយមានជំនួយពីក្រុមមន្ត្រីមូលដ្ឋាន និងនគរបាល ឬមន្ត្រីយោធាទៅវិញ។ ក្នុងករណីមួយចំនួន ប្រជាពលរដ្ឋបានរៀបរាប់អំពីសកម្មភាពហិង្សា ក្នុងនោះរួមមាន ទាំងការដុតបំផ្លាញផ្ទះសម្បែងរបស់ខ្លួនពីសំណាក់មន្ត្រីយោធា និងការវាយដំពីសំណាក់សន្តិសុខប្រដាប់អាវុធការពារដីសម្បទានផងដែរ។ ក្នុងករណីមួយចំនួនទៀត ប្រជាពលរដ្ឋ ត្រូវបានបណ្តេញចេញពីដីរបស់ខ្លួនទាំងមិនបានទទួលសំណងពីរាជរដ្ឋាភិបាល ឬក្រុមហ៊ុនពាក់ព័ន្ធទាល់តែសោះ។ លើសពីនេះទៅទៀត អ្នកចូលរួមក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រនិងម្ចាស់ឆ្នោត តែងបានលើកឡើងម្តងហើយម្តងទៀត អំពីការលំបាកក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីរបស់ខ្លួន ដោយសារតែមានការទាមទារប្រាក់សំណូកពីមន្ត្រីមូលដ្ឋាន។




អភិបាលរងខេត្តក្រចេះ ឆ្លើយតបចំពោះការលើកឡើងពីបញ្ហានានា អំឡុងកិច្ចពិភាក្សារវាង អ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត នៅវត្តវេឡុអង្គារាមអូរឫស្សី ក្នុងភូមិស្រែស្តៅ ឃុំអូរឫស្សី ក្រុងក្រចេះ ខេត្តក្រចេះ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១២

នៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រនិងម្ចាស់ឆ្នោត ជារឿយៗ ប្រជាពលរដ្ឋបានសម្តែងកំហឹងរបស់ខ្លួន និងបានទាមទារឲ្យមានការឆ្លើយតបពីរាជរដ្ឋាភិបាលអំពីការបែកចែកដីដោយគ្មានភាពយុត្តិធម៌ កង្វះតម្លាភាពក្នុងការផ្តល់ដីសម្បទាន និងការមិនអើពើចំពោះប្រជាពលរដ្ឋដែលគ្មានដីធ្លី។ អ្នកចូលរួមក៏បានលើកឡើងថា ច្បាប់ភូមិបាលគ្មានប្រសិទ្ធភាព មិនអាចអនុវត្តបាន និងមានចន្លោះប្រហោងច្រើន។ អ្នកចូលរួម បានសម្តែងការខកចិត្តរបស់ខ្លួន បន្ទាប់ពីបានឮថា ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ បានច្រានចោលបញ្ហាដីធ្លីនេះ ជាមួយនឹងការលើកឡើងថា រដ្ឋតែង "អនុវត្តតាមច្បាប់" ដោយបានបដិសេធមិនបំពេញចន្លោះប្រហោងក្នុងច្បាប់ភូមិបាល ឬកង្វះការអនុវត្តច្បាប់ឡើយ។ ប្រជាពលរដ្ឋបានរាយការណ៍ម្តងហើយម្តងទៀតថា រាជរដ្ឋាភិបាល និងតុលាការ មិនបានជួយខ្លួនទេ។ អ្នកចូលរួម ក៏បាននិយាយជាញឹកញាប់ថា ខ្លួនមិនបានដឹងអ្វីសោះពីការធ្វើសម្បទានដីធ្លីនេះ ដោយសារតែមន្ត្រីរដ្ឋាភិបាលមិនបានជូនដំណឹង ហើយពួកគាត់ក៏មិនបានដឹងថា ដីរបស់ខ្លួននឹងត្រូវគេរឹបអូសដែរ រហូតទាល់តែអេស្កាវ៉ាទ័រឈូសឆាយដីមកដល់លើដីកម្មសិទ្ធិតែម្តង។

*នៅខេត្តកំពង់ឆ្នាំង អ្នកចូលរួមម្នាក់បានពន្យល់ថា លោកបានរស់នៅលើដីរបស់ខ្លួនចាប់តាំងពីឆ្នាំ ១៩៨១ មកម្ល៉េះ ប៉ុន្តែលោកមិនបានទទួលប័ណ្ណកម្មសិទ្ធិដីធ្លីនោះទេ បើទោះជាលោកបានដាក់ពាក្យស្នើសុំរួចហើយក៏ដោយ។ លោកបានស្នើសុំឲ្យអ្នកតំណាងរាស្ត្រពន្យល់ថា តើដីរបស់ប្រជាពលរដ្ឋនឹងទៅជាយ៉ាងណា ប្រសិនបើដីសម្បទានមាននៅគ្រប់ទីកន្លែងបែបនេះ។ "កសិករត្រូវការដីធ្លីដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅដ៏ខ្សត់ខ្សោយរបស់ខ្លួន។ តើកសិករ គឺជាម្ចាស់ដីស្រែរបស់ខ្លួន ឬក៏គ្រាន់តែជាកម្មករនៅលើដីរបស់ជនបរទេស?"*

ជាទូទៅ  អ្នកតំណាងរាស្ត្រមកពីគណបក្សតែមួយ  បានធ្វើការឆ្លើយតបស្រដៀងៗគ្នា ទាក់ទិននឹងបញ្ហាដីធ្លី ទោះបីជាពេលខ្លះ វិធីសាស្ត្រដោះស្រាយរបស់ពួកគេមានលក្ខណៈខុសៗគ្នា បើធៀបនឹងបណ្តាឆ្នាំមុនៗក៏ដោយ។ យ៉ាងណាមិញ អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានថ្លែងការពារគោលនយោបាយផ្តល់ដីសម្បទានរបស់រាជរដ្ឋាភិបាល ដោយបានលើកឡើងថា គោលនយោបាយនេះ គឺជាកត្តាចាំបាច់សម្រាប់ការអភិវឌ្ឍប្រទេសជាតិ។ អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាតែងបានទទូចថា រដ្ឋអនុវត្ត "នីតិរដ្ឋ" ប៉ុន្តែមិនដែលបានដោះស្រាយកង្វល់របស់ប្រជាពលរដ្ឋអំពីខ្លឹមសារច្បាប់តាំងពីដំបូងឡើយ។ អ្នកតំណាងរាស្ត្រគណបក្សកាន់អំណាចជាច្រើនរូបក៏បានបដិសេធថា ពុំមានបញ្ហាពាក់ព័ន្ធនឹងរឿងដីធ្លីទេ ហើយបានលើកឡើងថា ប្រជាពលរដ្ឋគ្រប់រូប សុទ្ធតែត្រូវបានការពារក្រោមច្បាប់នេះដោយភាពយុត្តិធម៌។ ជាច្រើនលើកច្រើនសារ អ្នកតំណាងរាស្ត្រ បានលើកយកពាក្យសម្តីនាយករដ្ឋមន្ត្រីដែលលើកឡើងថា "នាយករដ្ឋមន្ត្រី ហ៊ុន សែន តែងតែការពារប្រជាពលរដ្ឋ"។ អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមួយចំនួនបានព្រងើយកន្តើយចំពោះការត្អូញត្អែររបស់អ្នកចូលរួម ហើយមិនបានឆ្លើយតបឡើយ ដោយគ្រាន់តែនិយាយថា រាល់បញ្ហា និងជម្លោះដីធ្លី គឺជា "រឿងរបស់តុលាការ"។ អ្នកតំណាងរាស្ត្រផ្សេងៗទៀតបានធ្វើការធានាចំពោះមុខប្រជាពលរដ្ឋថា បញ្ហាដីធ្លីនេះ "កំពុងត្រូវបានដោះស្រាយ"។




បុរសម្នាក់លើកឡើងអំពីជម្លោះដីធ្លី អំឡុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ
និងម្ចាស់ឆ្នោត នៅវត្តអង្គមោល ភូមិលាងដៃ ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប
កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១២

អ្នកតំណាងរាស្ត្រគណបក្សប្រឆាំង បានរិះគន់គោលនយោបាយផ្តល់ដីសម្បទាននេះ ជាពិសេសគឺការផ្តល់ដីសម្បទានក្រោមកិច្ចសន្យា៩៩ឆ្នាំ និងការផ្តល់ដីសម្បទានទៅឲ្យក្រុមហ៊ុនបរទេសនានា។ ពួកគេបានលើកឡើងថា ដីទាំងនេះ គួរតែត្រូវបានរក្សាទុកសម្រាប់ប្រជាកសិករកម្ពុជា។ អ្នកតំណាងរាស្ត្រមួយរូបបានលើកឡើងថា "ប្រជាពលរដ្ឋ គួរតែជាម្ចាស់កម្មសិទ្ធិ

នៃអចលនទ្រព្យរបស់ខ្លួន និងមានសិទ្ធិធ្វើការសម្រេចចិត្តអំពីការអភិវឌ្ឍអចលនទ្រព្យនេះដោយខ្លួនឯង មិនមែនដោយរាជរដ្ឋាភិបាលនោះទេ”។ ពួកគេ បានរិះគន់ពីការដែលក្រុមហ៊ុននានាទទួលបានដីសម្បទានដោយស្ទើរតែមិនចាំបាច់ចំណាយធនធាន ឬបង់ពន្ធអ្វីទាល់តែសោះ។ អ្នកតំណាងរាស្ត្រគណបក្សប្រឆាំងបានគូសបញ្ជាក់ថា ក្រុមហ៊ុនមួយចំនួន មិនទាំងបានជួលកម្មករខ្មែរផងទេ។ អ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី មួយចំនួនក៏បានក្រើនរំឭកថា មិនយូរមិនឆាប់ប្រជាពលរដ្ឋកម្ពុជា នឹងក្លាយទៅជាជនភាគតិចនៅលើទឹកដីរបស់ខ្លួនឯងជាមិនខាន។




ប្រជាពលរដ្ឋ ចូលរួមក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រនិងម្ចាស់ឆ្នោត នៅភូមិក្រាំងបឹង ឃុំតាំងសំរោង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១២

អ្នកតំណាងរាស្ត្រគណបក្សប្រឆាំង បានរៀបរាប់អំពីការដែលអំពើពុករលួយចាក់ឫសយ៉ាងជ្រៅទៅក្នុងដំណើរការបែងចែកដីសម្បទាន ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី និងភាពជាម្ចាស់កម្មសិទ្ធិដីធ្លី។ ពួកគេបានឲ្យដឹងថា កិច្ចសន្យាដីធ្លីជាច្រើននៅក្នុងប្រទេសកម្ពុជា ពុំមានភាពស្របច្បាប់ទេ ហើយជារឿយៗ អាជ្ញាធរបានភូតភរថ្នាក់ដឹកនាំជាតិ ដើម្បីទទួលបានផលប្រយោជន៍ហិរញ្ញវត្ថុ។ អ្នកតំណាងរាស្ត្រគណបក្សប្រឆាំងក៏បានចោទប្រកាន់ផងដែរថា កសិករក្រីក្រមិនអាចទទួលបានយុត្តិធម៌ពីតុលាការ ឬដំណោះស្រាយតាមរយៈអាជ្ញាធរមូលដ្ឋាននោះទេ ប្រសិនបើខ្លួនមានទំនាស់ដីធ្លីជាមួយអ្នកមាន និងអ្នកមានអំណាចនោះ។ អ្នកតំណាងរាស្ត្រគណបក្សប្រឆាំងបានគូសបញ្ជាក់ថា ប្រជាពលរដ្ឋជាច្រើនពុំមានប័ណ្ណកម្មសិទ្ធិដីធ្លីឡើយ ហើយពួកគេត្រូវអាជ្ញាធរមូលដ្ឋានទាមទារប្រាក់សំណូកជាថ្នូរនឹងការទទួលបានប័ណ្ណកម្មសិទ្ធិ។ អ្នកតំណាងរាស្ត្រគណបក្សប្រឆាំងបានផ្តល់អនុសាសន៍ឲ្យអាជ្ញាធរពន្លឿនការចេញប័ណ្ណកម្មសិទ្ធិដីធ្លី និងអនុវត្តច្បាប់ដោយគ្មានអំពើពុករលួយ។

## ខ. ការរើសអើង អំពើពុករលួយ និងយុត្តិធម៌

បញ្ហាទី២ ដែលជាញឹកញាប់ត្រូវបានលើកឡើងនោះ គឺពាក់ព័ន្ធនឹងការរើសអើង អំពើពុករលួយ និងការអនុវត្តច្បាប់ដោយមិនស្មើភាពគ្នា។ ឆ្នាំនេះ អ្នកចូលរួមដែលមានចំនួនច្រើនជាងពេលណាៗទាំងអស់ បានរៀបរាប់អំពីការរើសអើងពីសំណាក់អាជ្ញាធរមូលដ្ឋានផ្អែកលើមូលដ្ឋាន

ទំនាក់ទំនងនយោបាយ ឬភាពខ្សត់ខ្សោយទ្រព្យសម្បត្តិ និងអំណាច។ អ្នកចូលរួមជាច្រើនបានលើកឡើងថា ការបែងចែកអំណោយជំនួយ មិនថាជាជំនួយស្បៀងអាហារ ឬជំនួយសម្រាប់ជនរងគ្រោះដោយសារទឹកជំនន់នោះទេ គឺសុទ្ធតែពោរពេញទៅដោយភាពលម្អៀង។ យ៉ាងណា-មិញ គ្រួសារដែលគាំទ្ររាជរដ្ឋាភិបាល បានទទួលជំនួយច្រើនបំផុត បើទោះជាវាគ្មានភាពចាំបាច់សម្រាប់ពួកគេក៏ដោយ។

*អ្នកចូលរួមម្នាក់មកពីខេត្តក្រចេះ បានត្អូញត្អែរថា ច្បាប់ការពារព្រៃឈើមិនត្រូវបានអនុវត្តន៍ដោយស្មើភាពនោះទេ។ ជាក់ស្តែង អាជ្ញាធរ ធ្លាប់បានចាប់ខ្លួនកសិករក្រីក្រ ក្រោមការចោទប្រកាន់ពីបទកាប់បំផ្លាញព្រៃឈើ ប៉ុន្តែបែរជាមិនអើពើចំពោះរថយន្តធំៗ ដែលដឹកជញ្ជូនឈើខុសច្បាប់ទៅកាន់ប្រទេសវៀតណាមជារៀងរាល់ថ្ងៃទៅវិញ។*

អ្នកចូលរួមក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រនិងម្ចាស់ឆ្នោត បានរៀបរាប់ពីករណីដែលទាក់ទងនឹងអាជ្ញាធរមូលដ្ឋាន៖ ទាមទារប្រាក់សំណូកសម្រាប់ការផ្តល់សេវាកម្មផ្សេងៗ ដូចជាការធ្វើសៀវភៅគ្រួសារ និងអត្តសញ្ញាណប័ណ្ណ គម្រាមទារប្រាក់ប្រជាពលរដ្ឋ ឬអនុវត្តច្បាប់មិនស្មើភាពគ្នា អាស្រ័យលើទ្រព្យសម្បត្តិ និងអំណាចរបស់ភាគីពាក់ព័ន្ធ។ ជារឿយៗ អ្នកចូលរួមបានរៀបរាប់អំពីការរើសអើងជនក្រីក្រដែលចង់បានយុត្តិធម៌ និងដែលអស់សង្ឃឹមក្នុងការដាក់ពាក្យបណ្តឹងទៅតុលាការ។ អ្នកចូលរួម ក៏បានសំដៅដល់វប្បធម៌និទណ្ឌភាពសម្រាប់អ្នកមានអំណាចជាញឹកញាប់។

*អ្នកចូលរួមម្នាក់មកពីខេត្តកំពង់ស្ពឺ បានចោទសួរថា "ប្រសិនបើ ថៅកែក្រុមហ៊ុនណាមួយរំលោភបំពានច្បាប់ តើពួកគេនឹងត្រូវទទួលទោសដែរឬយ៉ាងណា?" ចុះបើប្រធានភូមិ ឬមេឃុំ ប្រព្រឹត្តខុសវិញ តើពួកគេនឹងត្រូវទទួលទោសដែរឬទេ?" លោកបានលើកឧទាហរណ៍ថា សន្តិសុខក្រុមហ៊ុនឯកជន ធ្លាប់បានបាញ់ប្រហារប្រជាពលរដ្ឋ និងបំភិតបំភ័យប្រជាជនទៀតផង ប៉ុន្តែ មិនដែលបានទទួលទោសតាមច្បាប់ឡើយ។*

អ្នកចូលរួមមួយចំនួនតូចបានផ្សារភ្ជាប់បញ្ហាយុត្តិធម៌ និងសមធម៌ទៅនឹងសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ។ ស្ត្រីម្នាក់មកពីខេត្តកំពង់ចាម បានចោទសួរពីមូលហេតុដែលមេដឹកនាំប្រទេសផ្សេងៗទៀត តែងតែផ្លាស់ប្តូរ ខណៈដែលមេដឹកនាំកម្ពុជានៅតែជាមនុស្សតែមួយ។

*អ្នកចូលរួមម្នាក់មកពីខេត្តកំពង់ចាម បានត្អូញត្អែរថា ប្រជាពលរដ្ឋត្រូវបានគេចាត់ទុកថា ជាម្ចាស់អំណាចក្នុងប្រទេសកាន់លិទ្ធិប្រជាធិបតេយ្យ ប៉ុន្តែបែរជាមិនអាចធ្វើការសម្រេចចិត្តដោយពិតប្រាកដបានទៅវិញ។ "គណបក្សនានា បានត្រឹមតែបញ្ចុះបញ្ចូលអ្នកបោះឆ្នោតអំឡុងយុទ្ធនាការបោះឆ្នោត បន្ទាប់មកក្តោបក្តាប់អំណាចតែឯងប៉ុណ្ណោះ។"*

ជាទូទៅ អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា មិនបានឆ្លើយតបឲ្យបានក្បោះក្បាយចំពោះការត្អូញត្អែរទាំងនេះទេ ដោយគ្រាន់តែនិយាយថា សកម្មភាពដូចបានរៀបរាប់ខាងលើ គឺផ្ទុយពីច្បាប់ ហើយកម្រនឹងកើតមាន។ នីតិរដ្ឋ ត្រូវបានអនុវត្តន៍យ៉ាងត្រឹមត្រូវនៅទូទាំងប្រទេស ហើយតុលាការមានភាពឯករាជ្យ និងមិនពុករលួយឡើយ។ អ្នកតំណាងរាស្ត្រគណបក្សកាន់អំណាចមួយចំនួន បានលើកទឹកចិត្តប្រជាពលរដ្ឋ ឲ្យដាក់ពាក្យបណ្តឹងទៅអាជ្ញាធរជាន់ខ្ពស់ ប្រសិនបើខ្លួនជួបប្រទះអំពើពុករលួយ។ ក្នុងករណីខ្លះ អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បាននិយាយការពារខ្លួន ហើយបានលើកឡើងលើសពីម្តងថា ពុំមានអំពើពុករលួយ ឬការរើសអើងនៅក្នុងប្រទេសកម្ពុជាឡើយ បើទោះជាខ្លួនទើបនឹងបានផ្តល់ឧទាហរណ៍អំពីករណីទាំងពីរក៏ដោយចុះ។

*អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានគូសបញ្ជាក់ថា ពុំមានការបែងចែករវាងអ្នកក្រ និងអ្នកមាន និងរវាងអ្នកមានអំណាច និងអ្នកគ្មានអំណាច ក្នុងការអនុវត្តច្បាប់ទេ។*

អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមួយចំនួនតូច បានឆ្លើយតបចំពោះសំណួរពាក់ព័ន្ធនឹងបញ្ហាសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ប៉ុន្តែមានអ្នកតំណាងរាស្ត្រពីររូបដែលបានគូសបញ្ជាក់ពីតម្លៃអាទិភាពផ្សេងទៀតទៅវិញ។

*អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមួយរូបបានលើកឡើងថា "ភារកិច្ច និងកាតព្វកិច្ចមានសារៈសំខាន់ជាងលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។"*

អ្នកតំណាងរាស្ត្រគណបក្សប្រឆាំង បានឆ្លើយតបយ៉ាងម៉ឺងម៉ាត់ចំពោះបញ្ហាទាំងនេះ ដោយបានសម្តែងការយល់ស្របចំពោះក្តីកង្វល់របស់អ្នកចូលរួម និងការទាមទារឲ្យមានវិធានការតឹងរ៉ឹងប្រឆាំងអំពើពុករលួយ។ អ្នកតំណាងរាស្ត្រគណបក្សប្រឆាំងមួយចំនួន ថែមទាំងបានផ្តល់ស្ថិតិដូចជា ស្ថិតិដែលបង្ហាញថា ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់លេខ១៦៤ ក្នុងចំណោម១៨៣ប្រទេសដែលមានអំពើពុករលួយខ្លាំងបំផុតជាដើម។ ពួកគេ ក៏បានរៀបរាប់ពីការដែលអំពើពុករលួយធ្វើឲ្យប្រទេសកម្ពុជាធ្លាក់ទៅក្នុងភាពក្រីក្រ ដោយសារតែទឹកប្រាក់រាប់រយលានដុល្លារអាមេរិក បានហូរចូលក្នុងហោប៉ៅរបស់ថ្នាក់ដឹកនាំរដ្ឋាភិបាលពុករលួយជារៀងរាល់ឆ្នាំផងដែរ។ អ្នកតំណាងរាស្ត្រមួយរូបបានពន្យល់ថា ប្រទេសកម្ពុជា ត្រូវបានញាំញីដោយអំពើពុករលួយ ដូច្នេះហើយទើបបានជារាជរដ្ឋាភិបាលបង្កើតច្បាប់ដើម្បីការពារខ្លួនឯង។ ពួកគេ ក៏បានពណ៌នាយ៉ាងលម្អិតអំពីកង្វះតម្លាភាពក្នុងការធ្វើសេចក្តីសម្រេចរបស់រដ្ឋាភិបាល ក្នុងនោះរួមមានទាំងការចំណាយ និងបំណុលផងដែរ។ អ្នកតំណាងរាស្ត្រគណបក្សប្រឆាំង បានផ្តល់អនុសាសន៍មួយចំនួនសម្រាប់ដោះស្រាយ

បញ្ហាក្នុងប្រព័ន្ធតុលាការ ដូចជា ការហាមប្រាមចៅក្រម មិនឲ្យចូលជាសមាជិកគណបក្សនយោបាយជាដើម។ ពួកគេ ក៏បានលើកឡើងពីបញ្ហាប្រជាធិបតេយ្យផងដែរ ដោយបានចោទប្រកាន់ថា កម្ពុជាពុំទាន់មានលទ្ធិប្រជាធិបតេយ្យពិតប្រាកដនោះទេ ព្រោះប្រជាពលរដ្ឋគ្មានអំណាចពិតប្រាកដឡើយ។

*អ្នកតំណាងរាស្ត្រគណបក្សប្រឆាំង បាននិយាយថា អំណាចប្រជាពលរដ្ឋមានតែ "នៅលើក្រដាសប៉ុណ្ណោះ"។ លោក បានលើកឧទាហរណ៍អំពីការចាប់ខ្លួនប្រជាពលរដ្ឋដែលប៉ុនប៉ងប្រើអំណាចរបស់ខ្លួន តាមរយៈការធ្វើបាតុកម្មដោយសន្តិវិធី ដូចជាក្នុងករណីព្រៃឡង់ជាដើម។*

### គ. ហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍ

ប្រជាពលរដ្ឋដែលបានចូលរួមនៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត បានសំណូមពរឲ្យមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ ទំនប់ទឹក និងប្រព័ន្ធធារាសាស្ត្រជាដើម។ ពួកគេ ក៏បានលើកឡើងពីតម្រូវការចាំបាច់នូវសេវាកម្មជាមូលដ្ឋានផ្សេងៗផងដែរ ក្នុងនោះមានជាអាទិ៍ សេវាថែទាំសុខភាព អគ្គិសនី ការអប់រំ និងទឹកស្អាត។ មូលបទស្នូលនៃតម្រូវការទាំងនេះ គឺភាពក្រីក្រហើយប្រជាជនបានត្អូញត្អែរអំពីដំណើរការយឺតយ៉ាវក្នុងការអភិវឌ្ឍ។ អ្នកចូលរួមមួយចំនួនបានលើកឡើងថា គោលនយោបាយរបស់រាជរដ្ឋាភិបាល បានត្រឹមតែ "ធ្វើឲ្យប្រជាពលរដ្ឋកាន់តែក្រឡើងៗ" ប៉ុណ្ណោះ។

*អ្នកចូលរួមម្នាក់មកពីខេត្តកំពង់ចាម បានចោទសួរថា "ហេតុអ្វីបានជាប្រជាជនច្រើនជាង៥០% ជំពាក់បំណុលស្ថាប័នគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ខណៈដែលរាជរដ្ឋាភិបាលអះអាងថា មានកំណើនសេដ្ឋកិច្ចប្រាំមួយភាគរយនោះ?"*

អ្នកចូលរួម ក៏បានលើកឡើងអំពីការធ្លាក់ចុះតម្លៃផលិតផលកសិកម្មនៅប្រទេសកម្ពុជា និងកង្វះទីផ្សារសម្រាប់ផលិតផលរបស់ខ្លួនផងដែរ។ អ្នកចូលរួមជាច្រើននាក់ បានស្នើឲ្យអ្នកតំណាង-រាស្ត្រចែករំលែកព័ត៌មានអំពីគោលនយោបាយអភិវឌ្ឍន៍ និងកសិកម្មជាក់លាក់របស់គណបក្សខ្លួន។ អ្នកចូលរួមមួយចំនួនតូច ចង់មានការយល់ដឹងប្រសើរជាងមុនអំពីប្រភពថវិកាសម្រាប់ការអភិវឌ្ឍ ហើយបានចោទសួរអំពីបំណុលរបស់ប្រទេសជាតិ។ អ្នកចូលរួម ក៏បានចោទសួរអំពីឈ្មោះថ្នាក់ដឹកនាំនៅលើគម្រោងអភិវឌ្ឍន៍នីមួយៗ និងបានសួរថា តើថវិកាសម្រាប់អនុវត្តន៍គម្រោងទាំងនោះ ពិតជាបានមកពីបុគ្គលទាំងនោះមែន ឬយ៉ាងណា។




ឯកឧត្តម កាទើ គួយ៉េប អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា និង ឯកឧត្តម ឡុង រី អ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី អំឡុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត នៅវត្តវេឡុអង្គារាមអូរឫស្សី ក្នុងភូមិស្រែស្ដៅ ឃុំអូរឫស្សី ក្រុងក្រចេះ ខេត្តក្រចេះ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១២

ជាទូទៅ អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានឆ្លើយតបដោយស៊ីសង្វាក់គ្នាចំពោះកង្វល់អំពីការអភិវឌ្ឍ។ ស្ទើរតែទាំងអស់នៃអ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានគូសបញ្ជាក់ថា ប្រទេសកម្ពុជាមានការអភិវឌ្ឍ និងភាពរីកចម្រើនជាងរបបប៉ុលពត ហើយថាប្រជាពលរដ្ឋ គួរតែទទួលស្គាល់ការពិតដែលគណបក្សប្រជាជនកម្ពុជា បាន"កសាងប្រទេសតាំងពីបាតដៃទទេ"។ ពួកគេបានលើកឧទាហរណ៍អំពីការវិនិយោគពីបរទេសថា ជាភស្តុតាងបង្ហាញពីទំនុកចិត្តរបស់វិនិយោគិនលើប្រទេសកម្ពុជា។ ជាការឆ្លើយតបចំពោះការត្អូញត្អែរអំពីតម្លៃ ឬកង្វះទីផ្សារ អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានពន្យល់ថា ប្រទេសកម្ពុជា ប្រកាន់យកគោលការណ៍ទីផ្សារសេរី ហើយបានណែនាំប្រាប់ប្រជាពលរដ្ឋកុំឲ្យលក់ទំនិញរបស់ខ្លួន ប្រសិនបើគេឲ្យតម្លៃទាបពេក។ ពួកគេក៏បានទទូចហើយទទូចទៀតឲ្យប្រជាពលរដ្ឋមានការអត់ធ្មត់ ដោយបានលើកហេតុផលថា ការអភិវឌ្ឍ ត្រូវការពេលវេលា។ អ្នកតំណាងរាស្ត្រគណបក្សកាន់អំណាចក៏បានលើកទឹកចិត្តប្រជាពលរដ្ឋឲ្យចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ដើម្បីជួយកំណត់អាទិភាពនៃការអភិវឌ្ឍ ហើយក្នុងកំឡុងពេលនៃកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនោះ ពួកគេ ជាញឹកញាប់ បានប្រគល់បញ្ហាទាំងនេះឲ្យទៅអាជ្ញាធរមូលដ្ឋានដោះស្រាយ។

*អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានសុំឲ្យអ្នកស្តាប់ចាំថា "ប្រទេសទាំងអស់សុទ្ធតែមានបំណុល ប៉ុន្តែប្រទេសក្រៅ ប្រាកដជាមិនផ្តល់ប្រាក់កម្ចីទេ ប្រសិនបើពួកគេមិនមានទំនុកចិត្តថាកម្ពុជា អាចសងបំណុលវិញបាននោះ" ។*

អ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស បានបញ្ចេញប្រតិកម្មតបដោយផ្ទាល់ទៅនឹងការលើកឡើងរបស់គណបក្សកាន់អំណាច ហើយបានលើកពីមូលហេតុនៃការអភិវឌ្ឍយឺតយ៉ាវថា ដោយសារអំពើពុករលួយ អសមត្ថភាព និងគោលនយោបាយទន់ខ្សោយរបស់រដ្ឋាភិបាល។ អ្នកតំណាងរាស្ត្រគណបក្សប្រឆាំងមួយចំនួន បានឯកភាពជាមួយអ្នកតំណាង-រាស្ត្រគណបក្សប្រជាជនកម្ពុជាថា ប្រទេសកម្ពុជាមានភាពរីកចម្រើនជាងកាលពីឆ្នាំ១៩៧៩មែន ប៉ុន្តែបានបន្ថែមថា ភាពរីកចម្រើននេះមិនមែនជា "សមិទ្ធផលគួរឲ្យស្ញប់ស្ញែង" នោះទេ។ ពួកគេក៏បានចោទសួរពីមូលហេតុដែលប្រទេសកូរ៉េខាងត្បូងចំណាយពេលត្រឹមតែ ២០ឆ្នាំ ដើម្បីប្រែក្លាយពីប្រទេសក្រីក្រទៅជាប្រទេសអភិវឌ្ឍន៍ ក្រោយសម័យសង្គ្រាម ផ្ទុយពីប្រទេសកម្ពុជា ដែលនៅតែមានការអភិវឌ្ឍតិចតួចក្នុងរយៈពេលជាង៣០ឆ្នាំមកនេះ។ អ្នកតំណាងរាស្ត្រគណបក្សប្រឆាំងមួយចំនួនបានបន្ថែមថា ការលើកឡើងរបស់រដ្ឋាភិបាលដែលថា ប្រជាពលរដ្ឋ គួរតែពេញចិត្តនឹងអ្វីដែលខ្លួនមានសព្វថ្ងៃនេះ គឺជាការមើលស្រាលចំណេះដឹងរបស់ប្រជាពលរដ្ឋ។

*អ្នកតំណាងរាស្ត្រគណបក្សប្រឆាំងមួយរូប បានមានប្រសាសន៍ថា "ពិតណាស់ ប្រទេស កម្ពុជាមានភាពរីកចម្រើនជាងឆ្នាំ១៩៧៩មែន។ ប៉ុន្តែសំណួរគឺនៅត្រង់ថា តើប្រទេសកម្ពុជាកំពុងអភិវឌ្ឍន៍ឆាប់រហ័សល្មមហើយ ឬយ៉ាងណា? វាមានរយៈពេលជាង ៣០ឆ្នាំហើយ" ។*

គណបក្សប្រឆាំង បានពន្យល់ថា ការអភិវឌ្ឍយឺតយ៉ាវនេះ គឺដោយសារតែប្រាក់ទាំងប៉ុន្មានបានហូរចូលទៅក្នុងហោប៉ៅរបស់ថ្នាក់ដឹកនាំរដ្ឋាភិបាល និងជនបរទេស ហេតុដូច្នេះហើយទើប "ការអភិវឌ្ឍមានភាពមិនសមប្រកប" បែបនេះ។ អ្នកតំណាងរាស្ត្រគណបក្សប្រឆាំង បានស្នើឲ្យមានការកែប្រែគោលនយោបាយកសិកម្ម និងការអន្តរាគមន៍ខ្លះ ចំពោះការកំណត់តម្លៃនៅលើទីផ្សារ។ ពួកគេ ក៏បានលើកឡើងពីភាពចាំបាច់ក្នុងការរៀបចំគម្រោងថវិកា និងការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុប្រកបដោយតម្លាភាពនៅក្នុងជួររដ្ឋាភិបាលផងដែរ។

*អ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី ម្នាក់បានលើកឡើងថា ប្រជាពលរដ្ឋកំពុងរស់នៅក្នុងភាពក្រីក្រដោយសារតែអំពើពុករលួយ។ "អំពើពុករលួយនៅក្នុងប្រទេសកម្ពុជា ធ្វើឲ្យបាត់បង់ធនធានរបស់ប្រជាជនកម្ពុជា។ មានតែអ្នកមានទេទើបមានសុភមង្គល"។*

អ្នកតំណាងរាស្ត្រគណបក្សប្រឆាំងក៏បានលើកឡើងអំពីជំនួយ និងប្រាក់កម្ចីយ៉ាងច្រើន សម្រាប់ការអភិវឌ្ឍផងដែរ ដោយពន្យល់ថា កញ្ចប់ថវិកានេះ គឺសម្រាប់រដ្ឋាភិបាលមិនមែន គណបក្សនយោបាយឡើយ។ ពួកគេ បានសង្កត់ធ្ងន់អំពីបន្ទុកដោយសារបំណុលលើសេដ្ឋកិច្ច របស់ប្រទេសជាតិ ហើយជាញយដង បានបង្ហាញតួលេខ និងស្ថិតិបំណុល ដែលមានការកើនឡើង ជាលំដាប់។ ទាក់ទងនឹងឈ្មោះបុគ្គល ក៏ដូចជាឈ្មោះគណបក្សនយោបាយនៅលើគម្រោង អភិវឌ្ឍន៍នានាវិញ គណបក្សប្រឆាំងបានពន្យល់ថា គម្រោងអភិវឌ្ឍន៍ទាំងនោះ បានទទួលមូលនិធិ ពីរដ្ឋាភិបាលតាមរយៈជំនួយ និងពន្ធ មិនមែនតាមរយៈគណបក្សប្រជាជនកម្ពុជា ឬនាយករដ្ឋមន្ត្រី នោះទេ។

## ៣. លទ្ធផលនៃកិច្ចពិភាក្សាក្រុមគោលដៅ

វិទ្យាស្ថានជាតិ NDI បានរៀបចំកិច្ចពិភាក្សាក្រុមគោលដៅ ដែលមានការចូលរួមពីអ្នកដែល ត្រូវបានជ្រើសរើសសម្រាប់កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ដើម្បីប្រមូលព័ត៌មាន បែបគុណភាព សម្រាប់ការវាយតម្លៃអំពីប្រសិទ្ធភាពនៃកិច្ចពិភាក្សានេះលើចំណេះដឹង និង ឥរិយាបទរបស់អ្នកចូលរួមចំពោះរដ្ឋសភា ក៏ដូចជាសមាជិកសភា និងការយល់ឃើញរបស់ ពួកគាត់អំពីជម្រើសនយោបាយ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ តាមរយៈកិច្ចពិភាក្សា ទាំងនេះ វិទ្យាស្ថានជាតិ NDI បានប្រមូលព័ត៌មានអំពីទម្លាប់ទូទៅក្នុងការដោះស្រាយបញ្ហានៅក្នុង សហគមន៍ និងកម្រិតនៃទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងអ្នកតំណាងរាស្ត្រ។

កិច្ចពិភាក្សាក្រុមគោលដៅនេះ ត្រូវបានរៀបចំឡើងមុន និងក្រោយកិច្ចពិភាក្សារវាង អ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតចំនួន៨លើក[9] ក្នុងចំណោមកិច្ចពិភាក្សាទាំង១៤លើក[10] ដែលបាន ប្រព្រឹត្តទៅចន្លោះពីខែវិច្ឆិកា ឆ្នាំ២០១១ ដល់ខែកញ្ញា ឆ្នាំ២០១២។ អ្នកចូលរួមភាគច្រើនគឺជាកសិករ ដែលមានអាយុចាប់ពី២៥ឆ្នាំឡើងទៅ។ កិច្ចពិភាក្សាក្រុមគោលដៅនេះ មានរយៈពេលប្រហែល ១ម៉ោង ហើយមានអ្នកចូលរួមជាមធ្យមចំនួន១២នាក់ ក្នុងនោះមានស្ត្រីជាង៥០%។ អំឡុង កិច្ចពិភាក្សាក្រុមគោលដៅ ដែលធ្វើឡើងនៅមុន និងក្រោយកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និង ម្ចាស់ឆ្នោតបន្តិច អ្នកសម្របសម្រួលរបស់វិទ្យាស្ថានជាតិ NDI បានសួរសំណួរស្រដៀងៗគ្នា និង បានរៀបចំលំហាត់ពាក្យជាមួយក្រុមអ្នកចូលរួមដដែល ដើម្បីកត់សម្គាល់នូវការផ្លាស់ប្តូរណាមួយ។ វិទ្យាស្ថានជាតិ NDI បានរៀបចំកិច្ចពិភាក្សាក្រុមគោលដៅនេះជាភាសាខ្មែរ និងបានថតកិច្ចពិភាក្សា នេះទុកជាឯកសារ។ បន្ទាប់មក វិទ្យាស្ថានជាតិ NDI កត់ត្រាជាអក្សរ រួចប្រែសម្រួលទៅជាភាសា អង់គ្លេសវិញ។

---

[9] ក្នុងអំឡុងពេលសរសេររបាយការណ៍នេះ មានកិច្ចពិភាក្សាក្រុមគោលដៅ ត្រូវបានរៀបចំឡើងតែក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតចំនួនប្រាំពីរប៉ុណ្ណោះ។ លទ្ធផលបន្ទាប់មកទៀត គឺផ្អែកលើកិច្ចពិភាក្សាក្រុមគោលដៅចំនួនប្រាំពីរ ដោយមិនរាប់បញ្ចូល កិច្ចពិភាក្សាក្រុមគោលដៅចុងក្រោយនៅខេត្តកំពង់ធំ។

[10] កិច្ចពិភាក្សាក្រុមគោលដៅ មិនត្រូវបានរៀបចំឡើងសម្រាប់កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតចំនួនប្រាំមួយលើក ដែលរៀបចំ និងសាកល្បងវិធីសាស្ត្រនៃកិច្ចពិភាក្សាក្រុមគោលដៅមួយផ្សេងទៀត សម្រាប់ការស្រាវជ្រាវអំពីការវាយតម្លៃឥទ្ធិពលរបស់ វិទ្យាស្ថានជាតិNDI។

ការយល់ដឹងអំពីរដ្ឋសភារបស់អ្នកចូលរួម ក្នុងកិច្ចពិភាក្សាក្រុមគោលដៅមុនកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ឃើញថានៅមានកម្រិតទាប។ អ្នកចូលរួមភាគច្រើនក្នុងក្រុមកិច្ចពិភាក្សាក្រុមគោលដៅទាំងប្រាំពីរលើក មិនយល់ពីការងាររបស់រដ្ឋសភាទេ។ អ្នកឆ្លើយតបបានបញ្ជាក់ថា ខ្លួនមិនទាំងដឹងថារដ្ឋសភាគឺជាអ្វីផងទេ ឬបើមិនដូច្នេះទេ គឺបានផ្តល់ចម្លើយមិនច្បាស់លាស់តែម្តង។ ក្នុងករណីខ្លះ អ្នកចូលរួមយល់ច្រឡំថា "រដ្ឋាភិបាល និងរដ្ឋសភា គឺតែមួយ" ទៀតផង។ ក្រុមគោលដៅនៅខេត្តកណ្តាល ឆ្លើយបានល្អជាង ដោយអ្នកចូលរួមមួយចំនួនបានលើកឡើងពីមុខងារតាក់តែងច្បាប់របស់រដ្ឋសភា ហើយមានម្នាក់ថែមទាំងបាននិយាយពីតួនាទីពិនិត្យតាមដានរបស់រដ្ឋសភាទៀតផង។

ភ្លាមៗក្រោយកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត កិច្ចពិភាក្សាក្រុមគោលដៅនេះ បានស្តែងឲ្យឃើញពីការផ្លាស់ប្តូរនូវចំណេះដឹងរបស់អ្នកចូលរួម ដោយសារការចូលរួមនៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនេះ។ ពួកគាត់ មានការយល់ដឹងច្រើនជាងមុនអំពីតួនាទី និងមុខងាររបស់រដ្ឋសភា ដោយក្នុងក្រុមនីមួយៗ យ៉ាងហោចណាស់ក៏មានអ្នកចូលរួមខ្លះ អាចបកស្រាយពីការងាររបស់រដ្ឋសភា។ អ្វីដែលគួរឲ្យកត់សម្គាល់នោះ គឺថាអ្នកឆ្លើយតបមួយចំនួនអាចធ្វើការបែងចែករវាងរដ្ឋាភិបាល និងស្ថាប័ននីតិប្បញ្ញត្តិ ទោះជាការបែងចែកនោះមិនច្បាស់លាស់គ្រប់ពេលក៏ដោយ។ អ្នកចូលរួមម្នាក់មកពីខេត្តកំពង់ស្ពឺ បាននិយាយថា "រដ្ឋសភាបង្កើតសុខសន្តិភាពជូនប្រទេសជាតិ ខ្ញុំមិនដឹងថារដ្ឋាភិបាលធ្វើអ្វីខ្លះនោះទេ"។ ប៉ុន្តែ សូម្បីតែអ្នកចូលរួមដែលអាចកំណត់មុខងាររបស់រដ្ឋសភា ក៏ដឹងត្រឹមតែពីមុខងារបង្កើតច្បាប់របស់រដ្ឋសភា ហើយអាចនិយាយពីតួនាទីជាអ្នកតំណាងរាស្ត្រម្តងម្កាលប៉ុណ្ណោះ។ មានតែប្រជាពលរដ្ឋម្នាក់គត់ នៅក្នុងកិច្ចពិភាក្សាក្រុមគោលដៅទាំងប៉ុន្មាន ដែលបាននិយាយអំពីតួនាទីពិនិត្យតាមដានរបស់រដ្ឋសភា។

**ចំនួននៃកិច្ចពិភាក្សាក្រុមគោលដៅ ដែលអ្នកចូលរួមអាចកំណត់មុខងាររបស់សភាជាតិ**



មុនពេលមានកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត អ្នកចូលរួមក្នុងកិច្ចពិភាក្សាក្រុមគោលដៅនេះ បានបង្ហាញអំពីការយល់ដឹងស្រពេចស្រពិល និងមិនច្បាស់លាស់អំពីតួនាទីរបស់សមាជិកសភា។ អ្នកចូលរួមភាគច្រើនបានឆ្លើយថា អ្នកតំណាងរាស្ត្រត្រូវ "ជួយប្រជាពលរដ្ឋ" "ការពារប្រជាពលរដ្ឋ" ឬ "ដោះស្រាយបញ្ហា" ហើយអ្នកចូលរួមភាគច្រើនមានជំនឿថា ការងាររបស់អ្នកតំណាងរាស្ត្រ គឺត្រូវផ្តល់អំណោយ និងសេវាកម្មជាក់ស្តែង ភាគច្រើនគឺសំដៅទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធជូនម្ចាស់ឆ្នោតរបស់ខ្លួនដោយផ្ទាល់។ មុនកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតចាប់ផ្តើម គ្មានអ្នកចូលរួមក្នុងកិច្ចពិភាក្សាក្រុមគោលដៅណាម្នាក់ឆ្លើយថា តួនាទីរបស់អ្នកតំណាងរាស្ត្រមានដូចជា ការតាក់តែងច្បាប់ ឬការត្រួតពិនិត្យតាមដានសកម្មភាពរបស់រដ្ឋាភិបាលឡើយ ក្នុងនោះមានតែម្នាក់និយាយពីតួនាទីជាអ្នកតំណាងរបស់សមាជិកសភា។

ជំនឿរបស់អ្នកចូលរួមលើការទទួលខុសត្រូវរបស់អ្នកតំណាងរាស្ត្រ បានស្តែងចេញច្បាស់បំផុត នៅពេលចាប់ផ្តើមពិភាក្សាអំពីការរំពឹងទុករបស់ពួកគាត់ពីអ្នកតំណាងរាស្ត្ររបស់ខ្លួន។ នៅក្នុងកិច្ចពិភាក្សាក្រុមគោលដៅស្ទើរតែទាំងអស់ អ្នកចូលរួមរំពឹងថា អ្នកតំណាងរាស្ត្រ នឹងផ្តល់អំណោយ និងជំនួយអភិវឌ្ឍន៍។ ផ្លូវថ្នល់ ប្រឡាយទឹក ស្ពាន អគ្គិសនី សាលារៀន មណ្ឌលសុខភាព និងបង្គន់អនាម័យ ត្រូវបានអ្នកចូលរួមលើកឡើងច្រើនបំផុត។ ក្រុមអ្នកចូលរួមបានបង្ហាញពីក្តីរំពឹងរបស់ខ្លួនច្រើនជាងឆ្នាំមុនៗថា អ្នកតំណាងរាស្ត្រ ត្រូវដោះស្រាយបញ្ហាដីធ្លី។ អ្នកឆ្លើយម្នាក់មកពីខេត្តកំពង់ឆ្នាំងបាននិយាយថា គាត់ចង់ឲ្យអ្នកតំណាងរាស្ត្រ "យកដីរបស់យើងមកវិញ"។

ការយល់ដឹងរបស់អ្នកចូលរួមអំពីតួនាទីជាក់លាក់របស់អ្នកតំណាងរាស្ត្រ បានបង្ហាញនូវការផ្លាស់ប្តូរបន្តិចបន្តួច បន្ទាប់ពីការពិភាក្សារវាងតំណាងរាស្ត្រ និងម្ចាស់ឆ្នោតបញ្ចប់ ក្នុងនោះមានអ្នកចូលរួមក្នុងកិច្ចពិភាក្សាក្រុមគោលដៅនេះមួយចំនួនតូចប៉ុណ្ណោះ ដែលនិយាយអំពីមុខងារបង្កើតច្បាប់ និងមុខងារជាអ្នកតំណាងបន្ថែមពីលើការផ្តល់ជំនួយ។ អ្នកឆ្លើយតបម្នាក់មកពីខេត្តកំពង់ស្ពឺបាននិយាយយ៉ាងជាក់លាក់ថា អ្នកតំណាងរាស្ត្រ ត្រូវ "ចុះសួរសុខទុក្ខម្ចាស់ឆ្នោត"។ អ្នកចូលរួមម្នាក់មកពីខេត្តកណ្តាល បាននិយាយថា "ខ្ញុំ បានបោះឆ្នោតឲ្យពួកគាត់ ប៉ុន្តែរយៈពេលបួនឆ្នាំមកនេះ ខ្ញុំមិនដែលបានឃើញអ្នកតំណាងរាស្ត្ររបស់ខ្ញុំទេ។ ខ្ញុំ មានបញ្ហាច្រើនណាស់ ហើយខ្ញុំចង់ជួបអ្នកតំណាងរាស្ត្ររបស់ខ្ញុំ ដើម្បីសុំជំនួយ ប៉ុន្តែខ្ញុំមិនដឹងថាត្រូវទៅរកពួកគាត់នៅឯណាឡើយ"។ អ្នកចូលរួមក្នុងកិច្ចពិភាក្សាក្រុមគោលដៅច្រើនលើសលប់បានបន្តក្តីរំពឹងថា ខ្លួននឹងទទួលបានហេដ្ឋរចនាសម្ព័ន្ធសំខាន់ៗ ដូចជា ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ និងសាលារៀនពីអ្នកតំណាងរាស្ត្រ។ ទោះជាយ៉ាងណា ពួកគាត់ ក៏ឧស្សាហ៍បង្ហាញពីក្តីរំពឹងថា អ្នកតំណាងរាស្ត្រនឹងជួយដោះស្រាយបញ្ហាដីធ្លី ផ្តល់យុត្តិធម៌ និងចុះសួរសុខទុក្ខខ្លួនញឹកញាប់ជាងមុនដែរ។

អ្នកចូលរួមនៅកិច្ចពិភាក្សាក្រុមគោលដៅ មុនកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត មានការរំពឹងច្បាស់លាស់អំពីលក្ខណៈសម្បត្តិរបស់អ្នកតំណាងរាស្ត្រ ដែលពួកគេចង់បាននោះគឺ សមត្ថភាព សន្តានចិត្តល្អ មានសុភវិនិច្ឆ័យ ស្អាតស្អំ មានការអប់រំ និងមានសីលធម៌ ហើយការរំពឹងបែបនេះ មិនបានផ្លាស់ប្តូរទេ ក្រោយកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ អ្នកចូលរួមជាច្រើន បាននិយាយថា អ្នកតំណាងរាស្ត្រគួរតែ "ចុះសួរសុខទុក្ខ

ប្រជាពលរដ្ឋឲ្យបានញឹកញាប់”។ ការយល់ឃើញពីអត្ថន័យនៃពាក្យ “អ្នកតំណាងរាស្ត្រ” មានលក្ខណៈស្រពេចស្រពិល ហើយជាទូទៅ គឺវិជ្ជមាន ដោយពួកគាត់គិតថា អ្នកតំណាងរាស្ត្រ គឺជា “អ្នកដោះស្រាយបញ្ហា”។ អ្នកឆ្លើយម្នាក់មកពីខេត្តបាត់ដំបង បាននិយាយថា “នៅពេលខ្ញុំឮពាក្យអ្នកតំណាងរាស្ត្រ ខ្ញុំមានអារម្មណ៍រំភើប ព្រោះខ្ញុំចង់ឃើញអ្នកតំណាងរាស្ត្ររបស់ខ្ញុំ”។ អ្នកឆ្លើយម្នាក់ទៀតមកពីខេត្តកំពង់ស្ពឺបាននិយាយថា “នៅពេលខ្ញុំឮពាក្យអ្នកតំណាងរាស្ត្រ ខ្ញុំគិតថា ប្រជាពលរដ្ឋបោះឆ្នោតឲ្យពួកគាត់ធ្វើជាម៉ែជាឪរបស់ប្រជាពលរដ្ឋកម្ពុជា”។ មានតែអ្នកចូលរួមម្នាក់គត់ដែលបាននិយាយថា “នៅពេលខ្ញុំឮពាក្យអ្នកតំណាងរាស្ត្រ ខ្ញុំគិតថា អ្នកតំណាងរាស្ត្រមិនដែលជួយដោះស្រាយបញ្ហាប្រជាពលរដ្ឋទេ”។ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺថា នៅពេលនិយាយអំពីអ្នកតំណាងរាស្ត្រ និន្នាការនយោបាយ មិនដែលស្តែងចេញឡើយ។

មុនកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត កិច្ចពិភាក្សាក្រុមគោលដៅ បង្ហាញថា កិច្ចប្រឹងប្រែងចុះជួយតាមមណ្ឌលបោះឆ្នោតរបស់អ្នកតំណាងរាស្ត្រ នៅមិនទាន់គ្រប់គ្រាន់ទេ ហើយអ្នកចូលរួម មិនធ្លាប់មានការប្រាស្រ័យទាក់ទងជាមួយអ្នកតំណាងរាស្ត្ររបស់ខ្លួនទាល់តែសោះ។ មានតែអ្នកឆ្លើយបីនាក់ប៉ុណ្ណោះ នៅក្នុងកិច្ចពិភាក្សាក្រុមគោលដៅទាំងអស់ អាចប្រាប់ឈ្មោះសមាជិកសភាតែម្នាក់គត់របស់រដ្ឋសភា។ ក្រោយកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតបញ្ចប់ អ្នកចូលរួមក្នុងកិច្ចពិភាក្សាជាមួយក្រុមទាំងអស់អាចប្រាប់ឈ្មោះអ្នកតំណាង-រាស្ត្រយ៉ាងហោចណាស់ក៏ម្នាក់ដែរ ក្នុងចំណោមអ្នកតំណាងរាស្ត្រទាំងអស់ដែលខ្លួនបានជួបអំឡុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។




ដើម្បីដោះស្រាយបញ្ហានៅក្នុងសហគមន៍របស់ខ្លួន អ្នកចូលរួមក្នុងកិច្ចពិភាក្សាក្រុមគោលដៅ ធ្លាប់បានស្វែងរកកិច្ចអន្តរាគមន៍ពីអាជ្ញាធរមូលដ្ឋានមានជាអាទិ៍ មេភូមិ អភិបាលស្រុក និងក្រុមប្រឹក្សាឃុំ/សង្កាត់ ឬអង្គការក្រៅរដ្ឋាភិបាល។ អ្នកចូលរួមភាគច្រើនមិនដែលមានទំនាក់ទំនងជាមួយអ្នកតំណាងរាស្ត្ររបស់ខ្លួនអំពីបញ្ហាណាមួយឡើយ។ មានតែអ្នកចូលរួមម្នាក់នៅក្នុងកិច្ចពិភាក្សាក្រុមគោលដៅចំនួនពីរប៉ុណ្ណោះ ដែលនិយាយថា ខ្លួនធ្លាប់បានទាក់ទងជាមួយអ្នកតំណាងរាស្ត្រ។ ថ្វីត្បិតតែខ្វះទំនាក់ទំនងបែបនេះ អ្នកចូលរួមក្នុងកិច្ចពិភាក្សាក្រុមគោលដៅ

បានទទួលស្គាល់ថា ពួកគាត់មានសិទ្ធិក្នុងការពាំនាំកង្វល់របស់ខ្លួនជូនអ្នកតំណាងរាស្ត្រ។ នៅពេលត្រូវបានសួរថា តើខ្លួននឹងទាក់ទងទៅអ្នកតំណាងរាស្ត្រក្នុងពេលអនាគតឬយ៉ាងណានោះ អ្នកចូលរួមភាគច្រើនបានឆ្លើយថា ខ្លួននឹងធ្វើដូច្នេះ។




ក្រៅពីទំនាក់ទំនងនៅមានកម្រិតជាមួយអ្នកតំណាងរាស្ត្ររបស់ខ្លួន អ្នកចូលរួមក្នុងកិច្ចពិភាក្សាក្រុមគោលដៅនេះ មិនបានដឹងពីសកម្មភាព ឬគំនិតផ្តួចផ្តើម ដែលអ្នកតំណាងរាស្ត្របានអនុវត្តតាងនាមឲ្យប្រជាពលរដ្ឋ ឬសហគមន៍របស់ខ្លួន ឬកិច្ចប្រឹងរបស់អ្នកតំណាងរាស្ត្រ ក្នុងការដោះស្រាយបញ្ហាជូនពួកគាត់ឡើយ។ ក្រោយកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនៅខេត្តកំពង់ស្ពឺបញ្ចប់ អ្នកចូលរួមបាននឹកឃើញថា អ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី មួយរូបធ្លាប់បានជួយដោះស្រាយជម្លោះដីធ្លី ទោះជាការនឹកឃើញនេះ ប្រហែលជាដោយសារតែការលើកឡើងរបស់អ្នកតំណាងរាស្ត្រនៅក្នុងអំឡុងនៃកិច្ចពិភាក្សា។

អ្នកចូលរួមជាច្រើនក៏បានរៀបរាប់ផងដែរ អំពីការចូលរួមដោយផ្ទាល់របស់ខ្លួន ក្នុងការកសាងសហគមន៍ ភាគច្រើន គឺក្នុងរូបភាពជាការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់គម្រោងអភិវឌ្ឍន៍ខ្នាតតូចនៅថ្នាក់មូលដ្ឋាន ឬការចូលរួមនៅក្នុងការប្រជុំរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់។ អ្នកចូលរួមភាគច្រើនក្នុងកិច្ចពិភាក្សាក្រុមគោលដៅទាំងអស់បានឆ្លើយថា ពួកគាត់មានអារម្មណ៍ថា ខ្លួនគឺជាផ្នែកមួយនៃដំណើរការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងសហគមន៍ដែរ។

តាមរយៈកិច្ចពិភាក្សាក្រុមគោលដៅ វិទ្យាស្ថានជាតិ NDI ក៏បានស្ទង់ពីការយល់ឃើញរបស់ប្រជាពលរដ្ឋចំពោះជម្រើស និងការប្រកួតប្រជែងផ្នែកនយោបាយផងដែរ។ ជារួម គឺមានការយល់ឃើញវិជ្ជមានចំពោះគណបក្សប្រឆាំង និងលិទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស មុនកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ ជាធម្មតា ប្រជាពលរដ្ឋបានរៀបរាប់អំពីតួនាទីរិះគន់កែលម្អបែបស្ថាបនារបស់គណបក្សប្រឆាំង។ អ្នកឆ្លើយម្នាក់មកពីខេត្តកំពង់ឆ្នាំង បានលើកឡើងថា " នៅពេលដែលខ្ញុំឮពាក្យ "គណបក្សប្រឆាំង" ខ្ញុំគិតថាត្រូវតែមានគណបក្សកាន់អំណាច និងគណបក្សប្រឆាំង"។ អ្នកចូលរួមផ្សេងៗទៀតមិនមានការវិនិច្ឆ័យអ្វីផ្សេងទេ ដោយគ្រាន់តែបានលើកឡើងថា "គណបក្សប្រឆាំងមានគំនិតផ្សេង"។ មានតែនៅក្នុងការពិភាក្សាក្រុមគោលដៅមួយគត់ ដែលបាន

បញ្ចេញទស្សនៈអវិជ្ជមាន។ អ្នកចូលរួមម្នាក់មកពីខេត្តកំពង់ចាមបាននិយាយថា "នៅពេលដែលយើងឮពាក្យ"គណបក្សប្រឆាំង" យើងគិតថាពួកគេប្រឆាំង ឬរិះគន់ដើម្បីឈ្នះការបោះឆ្នោត"។ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺថា អ្នកឆ្លើយម្នាក់នៅក្នុងកិច្ចពិភាក្សាក្រុមគោលដៅគិតថាគណបក្សប្រឆាំងតាមពិតគឺខុសច្បាប់ ៖ "គណបក្សប្រឆាំងធ្វើខុសច្បាប់ ប្រឆាំងនឹងច្បាប់"។

ក្រោយកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត មិនមានអ្នកចូលរួមនៅក្នុងកិច្ចពិភាក្សាក្រុមគោលដៅណាមួយ បង្ហាញពីទស្សនៈអវិជ្ជមានចំពោះគណបក្សប្រឆាំងទេ។ នៅខេត្តកំពង់ចាម ដែលអ្នកចូលរួមមានទស្សនៈអវិជ្ជមាន មុនកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតបានចាប់ផ្តើម គោលគំនិតនេះ បានផ្លាស់ប្តូរវិញទាំងស្រុងក្រោយបញ្ចប់កិច្ចពិភាក្សា ដោយអ្នកចូលរួមទាំងអស់ បានបង្ហាញទស្សនៈវិជ្ជមានចំពោះគណបក្សប្រឆាំង។ ដូចដែលអ្នកឆ្លើយម្នាក់បាននិយាយថា "នៅពេលយើងឮពាក្យ "គណបក្សប្រឆាំង" យើងគិតឃើញគណបក្សមួយដែលពិនិត្យតាមដានសកម្មភាពគណបក្សកាន់អំណាច"។ ជាថ្មីម្តងទៀត តួនាទីរិះគន់កែលម្អ និងការពិនិត្យតាមដានត្រូវបានរំលេចឡើង។" "នៅពេលដែលខ្ញុំឮពាក្យ "គណបក្សប្រឆាំង" ខ្ញុំគិតថារដ្ឋាភិបាលប្រាកដជាមិនដឹងអំពីកំហុសរបស់ខ្លួនទេ ប្រសិនបើមិនមានការរិះគន់របស់គណបក្សប្រឆាំងនោះ"។




ក្រោយកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតចប់ អ្នកសម្របសម្រួលរបស់វិទ្យាស្ថានជាតិ NDI បានសួរសំណួរមួយចំនួនទៅអ្នកចូលរួមក្នុងកិច្ចពិភាក្សាក្រុមគោលដៅ ដើម្បីវាស់ស្ទង់ការយល់ឃើញទូទៅរបស់ពួកគាត់ចំពោះកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ការយល់ឃើញរបស់ពួកគាត់ចំពោះការឆ្លើយតបរបស់អ្នកតំណាងរាស្ត្រ និងជំនឿទុកចិត្តរបស់ពួកគាត់លើសមត្ថភាពរបស់អ្នកតំណាងរាស្ត្រក្នុងការគោរពតាមការសន្យារបស់ខ្លួន។ជាទូទៅ អ្នកចូលរួមក្នុងកិច្ចពិភាក្សាក្រុមគោលដៅក្រោយកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត

បញ្ចប់ មានការពេញចិត្តចំពោះការឆ្លើយតបរបស់អ្នកតំណាងរាស្ត្រ ហើយគិតថាបញ្ហារបស់ខ្លួនបានទទួលការយកចិត្តទុកដាក់។ អ្នកចូលរួមភាគច្រើនបានបញ្ជាក់ថា ការយល់ឃើញរបស់ខ្លួនចំពោះអ្នកតំណាងរាស្ត្រ គឺមានលក្ខណៈប្រសើរជាងមុន ដោយសារតែកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនេះ។ មានតែប្រជាពលរដ្ឋពីរបីនាក់ប៉ុណ្ណោះដែលបានបន្ថែមថា ទោះជាទស្សនៈរបស់ពួកគាត់ចំពោះអ្នកតំណាងរាស្ត្រមានលក្ខណៈប្រសើរជាងមុន ពួកគាត់នៅតែចង់បានការប្រាស្រ័យទាក់ទង និងលទ្ធផលច្រើនជាងនេះ។

អ្នកចូលរួមក្នុងកិច្ចពិភាក្សាក្រុមគោលដៅ បានបង្ហាញនូវទំនុកចិត្តខ្ពស់លើអ្នកតំណាងរាស្ត្រក្រោយកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតបញ្ចប់ ហើយបាននិយាយថា ខ្លួនជឿថាអ្នកតំណាងរាស្ត្រនឹងចាត់វិធានការដោះស្រាយកង្វល់ដែលត្រូវបានលើកឡើង។ ទោះជាយ៉ាងណាក្តី ការរំពឹងក៏ត្រូវបានលើកឡើង ហើយប្រជាពលរដ្ឋចង់ឃើញការអនុវត្តជាក់ស្តែង។ អ្នកចូលរួមក្នុងកិច្ចពិភាក្សាក្រុមគោលដៅមួយបាននិយាយថា "យើងមិនទាន់មានទំនុកចិត្តលើអ្នកតំណាងរាស្ត្រនៅឡើយទេ ដរាបណាពួកគេមិនទាន់បានដោះស្រាយបញ្ហាទាំងអស់ដែលយើងបានលើកឡើងនៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត"។ អ្នកចូលរួមក៏បានបញ្ចេញទស្សនៈរបស់ខ្លួនចំពោះទង្វើរបស់អ្នកតំណាងរាស្ត្រផងដែរ។ អ្នកចូលរួមម្នាក់បាននិយាយថា "ខ្ញុំមិនសូវមានទំនុកចិត្តលើចំណាប់អារម្មណ៍របស់អ្នកតំណាងរាស្ត្រ ថាគាត់ជាតំណាងរបស់ខ្ញុំទេ ព្រោះពួកគាត់បានស្នើឲ្យអាជ្ញាធរមូលដ្ឋានដោះស្រាយបញ្ហាទាំងឡាយ ដែលត្រូវបានលើកឡើងជំនួសខ្លួន ហើយអាជ្ញាធរ មិនដែលដោះស្រាយបញ្ហាទាំងនោះសោះឡើយ"។

## ៤. សកម្មភាព និងលទ្ធផលក្រោយកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត[11]

ក្រោយកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនីមួយៗបញ្ចប់ វិទ្យាស្ថានជាតិ NDI បានតាមដានបញ្ហាចម្បងៗដែលអ្នកចូលរួមបានលើកឡើងការសន្យារបស់អ្នកតំណាងរាស្ត្រក្នុងការដោះស្រាយបញ្ហានីមួយៗ លទ្ធផលនៃការដោះស្រាយបញ្ហាផ្អែកលើរបាយការណ៍ផ្ទាល់របស់អ្នកតំណាងរាស្ត្រ ហើយលទ្ធផលនៃការដោះស្រាយបញ្ហាផ្អែកលើសេចក្តីរាយការណ៍របស់សហគមន៍។ បុគ្គលិកវិទ្យាស្ថានជាតិ NDI បានបន្តទំនាក់ទំនងជាមួយអ្នកតំណាងរាស្ត្រម្នាក់ៗដើម្បីពិភាក្សាពីសកម្មភាពរបស់ពួកគេ គិតចាប់តាំងពីថ្ងៃបញ្ចប់កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ដោយបានកត់ត្រាព័ត៌មានទុកក្នុងទម្រង់ពិនិត្យតាមដាន[12]។ ក្រៅពីនេះ ដៃគូក្នុងមូលដ្ឋានរបស់វិទ្យាស្ថានជាតិ NDI បានចុះតាមភូមិដែលមានរៀបចំកិច្ចពិភាក្សារវាងអ្នកតំណាង-រាស្ត្រ និងម្ចាស់ឆ្នោត និងតាមសហគមន៍ក្បែរខាង នៅក្នុងរយៈពេលប៉ុន្មានខែ ក្រោយការបញ្ចប់

---

[11] ក្នុងអំឡុងពេលសរសេររបាយការណ៍នេះ កិច្ចប្រជុំពិនិត្យតាមដានភាគច្រើន (តែមិនទាំងអស់) ត្រូវបានរៀបចំជាមួយអ្នកតំណាងរាស្ត្រ។ នៅក្នុងសហគមន៍មួយចំនួន ពុំមានពេលវេលាគ្រប់គ្រាន់ ចាប់តាំងពីកិច្ចប្រជុំរវាងអ្នកតំណាងរាស្ត្រ មិនម្ចាស់ឆ្នោតត្រូវបានរៀបចំធ្វើឡើងក្នុងការពិនិត្យតាមដានបន្ថែមនៅថ្នាក់មូលដ្ឋាន។ លទ្ធផលដែលបានរាយការណ៍នៅក្នុងរបាយការណ៍នេះ គ្រាន់តែជាផ្នែកមួយតែប៉ុណ្ណោះ។

[12] ជាធម្មតា បុគ្គលិកនៃវិទ្យាស្ថានជាតិ NDI បានជួបជាមួយអ្នកតំណាងរាស្ត្រនៅការិយាល័យអ្នកតំណាងរាស្ត្រ។ ជួនកាលអ្នកតំណាងរាស្ត្រទាំងអស់ មិនមានពេលវេលាសម្រាប់ការសម្ភាសន៍ដោយផ្ទាល់ទេ ហើយតាមសំណូមពររបស់ពួកគេ ពួកគេបានបំពេញទម្រង់ពិនិត្យតាមដានរបស់វិទ្យាស្ថានជាតិ NDI ដោយខ្លួនឯង។

កិច្ចពិភាក្សានេះ ដោយបានជួបសំណេះសំណាលជាមួយអ្នកធ្លាប់ចូលរួមក្នុងកិច្ចពិភាក្សានេះ និងអាជ្ញាធរមូលដ្ឋាន ដើម្បីសាកសួរអំពីការផ្លាស់ប្តូរ ឬភាពរីកចម្រើនណាមួយពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត និងដើម្បីពិនិត្យផ្ទៀងផ្ទាត់លើភាពត្រឹមត្រូវនៃរបាយការណ៍របស់អ្នកតំណាងរាស្ត្រ។ ភាគច្រើន សកម្មភាព និងលទ្ធផលក្នុងរបាយការណ៍របស់អ្នកតំណាងរាស្ត្រ ត្រូវបានបញ្ជាក់ថា ជាការពិត នឹងស្របតាមការសង្កេតនៅថ្នាក់សហគមន៍ពីសំណាក់មន្ត្រីមូលដ្ឋាន និងប្រជាពលរដ្ឋ។ បន្ទាប់មក លទ្ធផលទាំងនេះ ត្រូវបានប្រមូលចងក្រង និងរាយការណ៍ត្រឡប់ទៅសហគមន៍នីមួយៗវិញ ដោយដៃគូក្នុងមូលដ្ឋាន និងអ្នកស្ម័គ្រចិត្តរបស់វិទ្យាស្ថានជាតិ NDI នៅក្នុងខែសីហា និងខែកញ្ញា ឆ្នាំ២០១២។




លោកជំទាវ កែ ច័ន្ទមុនី អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា និង ឯកឧត្តម ជាម ច័ន្ទនី អ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី កំពុងពិនិត្យឯកសារអំឡុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ក្នុងភូមិក្រសាំងដុះឡើង ឃុំក្បាលទឹក ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១២

អ្នកតំណាងរាស្ត្រភាគច្រើន បានចាត់វិធានការដោះស្រាយកង្វល់ ដែលអ្នកចូលរួមបានលើកឡើងនៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ហើយអន្តរាគមន៍របស់ពួកគេមានជាច្រើនរូបភាព។ ជាញឹកញាប់ អ្នកតំណាងរាស្ត្រសរសេររបាយការណ៍ ឬលិខិតជូនស្ថានប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល។ ក្នុងករណីខ្លះ អ្នកតំណាងរាស្ត្របានជួបប្រជុំជាមួយអាជ្ញាធរមូលដ្ឋាន និងធ្វើអន្តរាគមន៍យ៉ាងសកម្មដើម្បីដោះស្រាយបញ្ហានីមួយៗ ដោយជារឿយៗ ពួកគាត់បានដើរតួនាទីជាអ្នកសម្រុះសម្រួលដ៏សំខាន់ក្នុងការដោះស្រាយជម្លោះផ្សេងៗ។ កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត និងការយកចិត្តទុកដាក់របស់អ្នកតំណាងរាស្ត្រក្រោយកិច្ចពិភាក្សានេះ បានជួយពន្លឿនផែនការអភិវឌ្ឍដែលមានស្រាប់សម្រាប់តំបន់ក្នុងមូលដ្ឋាន ជាពិសេស គឺសំណើសុំហេដ្ឋារចនាសម្ព័ន្ធតែម្តង។ ថ្វីត្បិតតែកង្វល់ភាគច្រើន ដែលត្រូវបាន

លើកឡើង មិនទទួលបានការដំណោះស្រាយដោយសារកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនេះដោយផ្ទាល់ក៏ពិតមែន ប៉ុន្តែកិច្ចពិភាក្សាទាំងនេះឃើញថា មានឥទ្ធិពលគួរឲ្យកត់សម្គាល់ ភាគច្រើនគឺក្នុងលក្ខណៈប្រយោលមិនស្តែងឲ្យឃើញច្បាស់ ហើយពេលខ្លះ គឺចេញជាដំណោះស្រាយយ៉ាងពេញលេញតែម្តង។ ទោះជាពុំមានការចូលរួមពាក់ព័ន្ធជាក់លាក់ពីសំណាក់អ្នកតំណាងរាស្ត្រ កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនេះ បានលាតត្រដាងពីសកម្មភាពមិនគម្បី និងច្រើនតែខុសច្បាប់ ដោយជារឿយៗ បានឈានដល់ការចាត់វិធានការជាផ្លូវការនៅថ្នាក់មូលដ្ឋាន ឬការបញ្ឈប់សកម្មភាពដោយអ្នកប្រព្រឹត្តខ្លួនឯងផ្ទាល់តែម្តង។

ដូចបានរៀបរាប់ខាងដើម អ្នកតំណាងរាស្ត្រឧស្សាហ៍សរសេរលិខិត ឬជួបជាមួយមន្ត្រីរដ្ឋាភិបាលពាក់ព័ន្ធនានា ដើម្បីផ្តោតការចាប់អារម្មណ៍លើបញ្ហាដែលបានលើកឡើងអំឡុងពេលកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ វិទ្យាស្ថានជាតិ NDI បានកត់ត្រាទុកនូវរាល់អន្តរាគមន៍ទាំងឡាយ បើទោះជាបញ្ហាទាំងនោះ ទីបំផុតនៅតែគ្មានដំណោះស្រាយក៏ដោយ ព្រោះវាជាការបង្ហាញពីឆន្ទៈ និងការប្តេជ្ញារបស់អ្នកតំណាងរាស្ត្រ។ ឧទាហរណ៍រួមមានៈ

- ឯកឧត្តម ចាន់ ចេង អ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី ប្រចាំខេត្តកណ្តាល បានសំណូមពរឲ្យក្រុមប្រឹក្សាស្រុកគណបក្ស សម រង្ស៊ី ជួបជាមួយមេឃុំឈើខ្មៅ ក្នុងស្រុកកោះធំ ដើម្បីពិភាក្សារកដំណោះស្រាយសម្រាប់បញ្ហាទាក់ទងនឹងក្រុមហ៊ុនបូមខ្សាច់មួយដែលបានបង្កផលប៉ះពាល់លើអ្នកភូមិចុងខ្សាច់។ ជាលទ្ធផល ក្រុមហ៊ុននេះ ក៏បានសម្រេចបញ្ឈប់ដំណើរការបូមខ្សាច់របស់ខ្លួន។
- ឯកឧត្តម យ៉ែម បុញ្ញឫទ្ធិ អ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស ប្រចាំខេត្តកំពង់ចាម បានផ្ញើលិខិតជាច្រើនជូនរដ្ឋាភិបាលអំពីជម្លោះរវាងអ្នកភូមិ ៣២ ៣៣ និង ៣៥ ជាមួយនឹងក្រុមហ៊ុន អាន ម៉ាឌី។
- ឯកឧត្តម យូ ហុកគ្រី អ្នកតំណាងរាស្ត្រគណបក្សនរោត្តមរណឫទ្ធិ ប្រចាំខេត្តកំពង់ចាម បានផ្ញើលិខិតអន្តរាគមន៍មួយច្បាប់ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីជួយរំដោះស្ត្រីបម្រើការងារតាមផ្ទះម្នាក់ ដែលត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ហើយត្រូវនិយោជក មិនអនុញ្ញាតឲ្យត្រឡប់មកមាតុប្រទេសវិញ។
- លោកជំទាវ ចែម សាវ៉ៃ អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ប្រចាំខេត្តកំពង់ចាម បានពិភាក្សាជាមួយក្រសួងអភិវឌ្ឍន៍ជនបទអំពីការជីកអណ្តូងទឹកចំនួន១០ នៅក្នុងស្រុកចំការលើ ដើម្បីឆ្លើយតបទៅនឹងសំណើសុំប្រភពទឹកស្អាតសម្រាប់ប្រើប្រាស់។
- ឯកឧត្តម ឡុង រី អ្នកតំណាងរាស្ត្រ គណបក្ស សម រង្ស៊ី ប្រចាំខេត្តក្រចេះ បានសរសេរលិខិតមួយច្បាប់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីឆ្លើយតបចំពោះពាក្យបណ្តឹងទាក់ទងនឹងជម្លោះដីធ្លីជាមួយក្រុមហ៊ុនវៀតណាមឈ្មោះ ដាយ ណាម (Dai Nam)។ គណៈកម្មាធិការដោះស្រាយវិវាទដីធ្លីប្រចាំខេត្តនេះ បានចុះមកធ្វើប្លង់ដីជាប្រព័ន្ធ

ឲ្យគ្រួសារចំនួន២០ ក្នុងចំណោម៥០គ្រួសារ។ ប៉ុន្តែ គ្រួសារចំនួន៣០ទៀត មិនទាន់បានទទួលប្លង់ដីរបស់ខ្លួននៅឡើយទេ។

- ឯកឧត្តម គួយ ប៊ុនរឿន អ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី បានឲ្យដឹងថា ឯកឧត្តម បានសរសេរសំបុត្រមួយច្បាប់ជូនលោកអភិបាលខេត្ត ប្រធានគណៈកម្មាធិការសុរិយោដីខេត្តកំពង់ចាម និងប្រធានរដ្ឋសភាជាតិ ដើម្បីស្នើសុំអន្តរាគមន៍ដោះស្រាយជម្លោះដីធ្លីរវាងភាគីពីរនៅភូមិខ្ពប។

តួនាទីរបស់អ្នកតំណាងរាស្ត្រ ដែលប្រហែលជាមានសារៈប្រយោជន៍បំផុត និងប្រើជាញឹកញាប់ជាទីបំផុត ក្រោយបញ្ចប់កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត គឺតួនាទីជាអ្នកចរចានៅក្នុងជម្លោះផ្សេងៗ ដោយវាបានជួយបង្កើតឱកាសសម្រាប់ការសម្រុះសម្រួល និងការបញ្ចុះបញ្ចូល ក្នុងនាមជាអ្នកតំណាងឲ្យផលប្រយោជន៍របស់អ្នកចូលរួម។ ឧទាហរណ៍រួមមាន៖

- ក្រុមប្រឹក្សាឃុំឈើខ្មៅ ក្នុងខេត្តកណ្ដាល របស់គណបក្ស សម រង្ស៊ី បាននាំអ្នកស្រុកនៅភូមិក្បាលជ្រោយ ទៅចុះឈ្មោះបោះឆ្នោតដោយគ្មានអត្តសញ្ញាណប័ណ្ណ ប៉ុន្តែមានឯកសារជំនួសត្រឹមត្រូវ។ ដំបូងឡើយ អ្នកភូមិទាំងនោះ មិនត្រូវបានអនុញ្ញាតឲ្យចុះឈ្មោះទេ ប៉ុន្តែអ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី ប្រចាំខេត្តកណ្ដាល បានជួយដាក់ពាក្យបណ្ដឹង ហើយទីបំផុតពួកគាត់ក៏ត្រូវបានអនុញ្ញាតឲ្យចុះឈ្មោះវិញ។
- ឯកឧត្តម អ៊ុំ សុខន អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ប្រចាំខេត្តតាកែវ បានស្នើឲ្យអភិបាលស្រុកចរចាជាមួយក្រុមហ៊ុនបូមខ្សាច់ ដែលបានធ្វើឲ្យខូចផ្លូវជាច្រើន ដោយសាររថយន្តដឹកទំនិញលើសទម្ងន់។ ទីបំផុត ក្រុមហ៊ុនបានយល់ព្រមជួសជុលផ្លូវនោះវិញ។
- ឯកឧត្តម សាន សាង អ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី ប្រចាំខេត្តកំពង់ចាម បានធ្វើការជាមួយក្រុមប្រឹក្សាឃុំគណបក្ស សម រង្ស៊ី ដើម្បីធានាធ្វើយ៉ាងណាឲ្យក្រុមហ៊ុន អាន ម៉ាឌី និងអាជ្ញាធរមូលដ្ឋាន អនុវត្តន៍តាមកិច្ចសន្យារបស់ខ្លួន ក្នុងការផ្ដល់ប័ណ្ណកម្មសិទ្ធិដីធ្លីជូនអ្នកភូមិ៣២ ៣៣ និង ៣៥ ប្រសិនបើពួកគេតម្រូវឲ្យអ្នកភូមិរើចេញពីដីរបស់ខ្លួន។ ក្រុមហ៊ុនក៏បានធ្វើតាមការសន្យា ហើយអ្នកភូមិត្រូវរើចេញ ប៉ុន្តែពួកគាត់ទទួលបានប័ណ្ណកម្មសិទ្ធិសម្រាប់ដីថ្មីរបស់ខ្លួន។
- ឯកឧត្តម គួយ ប៊ុនរឿន អ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី ប្រចាំខេត្តកំពង់ចាម បានរាយការណ៍ថា ក្រុមប្រឹក្សាស្រុកគណបក្ស សម រង្ស៊ី បានលើកឡើងពីជម្លោះដីធ្លីរវាងអ្នកភូមិកំពង់រាបក្រោម និងកំពង់ស្ដីលើ អំឡុងកិច្ចប្រជុំប្រចាំខែថ្នាក់ស្រុក ហើយទីបំផុតក៏បានឈានដល់ការសម្រុះសម្រួលគ្នារវាងមេភូមិទាំងពីរ។

នៅក្នុងករណីមួយចំនួនតូច កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត បានលើកទឹកចិត្តប្រជាពលរដ្ឋឲ្យចេះចាត់ចែងដោះស្រាយបញ្ហា ដែលពួកគេជួបប្រទះរួមគ្នា។ ឧទាហរណ៍រួមមាន៖

- ក្នុងខេត្តកំពង់ឆ្នាំង ក្រុមអ្នកភូមិបឹងកក់ បានជួបជាមួយតុលាការខេត្ត ទាក់ទងនឹងវិវាទដីធ្លីជាង៨,៥ហិចតា ជាមួយមេភូមិ។
- ប្រជាពលរដ្ឋ ៥២គ្រួសារ នៅភូមិឡពាង ខេត្តកំពង់ឆ្នាំង បានទៅតុលាការដើម្បីដោះស្រាយវិវាទដីធ្លីជាមួយក្រុមហ៊ុន KDC។ តុលាការមិនទាន់បានចេញសាលក្រមនៅឡើយទេ។
- ឯកឧត្តម ជាម ច័ន្ទនី អ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី ប្រចាំខេត្តកំពង់ឆ្នាំង បានស្នើឲ្យក្រុមប្រឹក្សាស្រុកគណបក្ស សម រង្ស៊ី ផ្តល់យោបល់ដល់អ្នកភូមិឡពាង អំពីវិធីជំរុញផែនការអភិវឌ្ឍន៍ខេត្ត ដើម្បីឆ្លើយតបទៅនឹងតាមសំណើសុំឲ្យជួសជុលផ្លូវមួយខ្សែប្រវែងពីរគីឡូម៉ែត្រ ពីភូមិឡពាង ទៅភូមិអូរតាសំ។

ជាការឆ្លើយតបចំពោះសំណើអភិវឌ្ឍន៍នេះ អ្នកតំណាងរាស្ត្របានដាក់សម្ពាធលើអាជ្ញាធរមូលដ្ឋានឲ្យពន្លឿនគម្រោង ឬគំនិតផ្តួចផ្តើមដែលមានក្នុងផែនការស្រាប់ ដោយជារឿយៗ ការដាក់សម្ពាធនេះបានផ្តល់លទ្ធផលសម្រាប់សហគមន៍។ ថ្វីត្បិតតែលទ្ធផលទាំងនេះមិនមែនទទួលបានដោយសារកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតដោយផ្ទាល់ក៏ពិតមែន ប៉ុន្តែកិច្ចពិភាក្សានេះ បានជួយលើកកម្ពស់ការយល់ដឹងជាចាំបាច់ និងបានផ្តល់ការលើកទឹកចិត្តដើម្បីពន្លឿនការចាត់វិធានការ ដែលពេលខ្លះមិនទាំងមានការចូលរួមពីអ្នកតំណាងរាស្ត្រផង។ នៅក្នុងករណីខ្លះ អ្នកតំណាងរាស្ត្រ អាចបញ្ចុះបញ្ចូលឲ្យមានកម្មវិធី ឬសកម្មភាពថ្មីដែលម្ចាស់ឆ្នោតបានស្នើឡើងប្រកបដោយប្រសិទ្ធភាព។ ឧទាហរណ៍រួមមាន៖

- ឯកឧត្តម ប៉ាល់ សំអឿន អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ប្រចាំខេត្តបន្ទាយមានជ័យ បានជួបជាមួយអភិបាលស្រុក និងបានស្នើឲ្យដាក់បញ្ចូលសំណើសុំផ្លូវមួយខ្សែក្នុងស្រុកស្វាយចេក សំណើសុំឲ្យជួសជុលផ្លូវលំនៅភូមិខ្លែងពណ៌ អាងទឹកមួយនៅភូមិខ្លែងពណ៌ និងផ្លូវក្រាលកៅស៊ូមួយខ្សែក្នុងភូមិកំណប់ ទៅក្នុងផែនការអភិវឌ្ឍន៍ខេត្តឆ្នាំ២០១២។ គម្រោងទាំងនេះសុទ្ធតែត្រូវបានត្រៀមអនុវត្តន៍ក្នុងឆ្នាំ២០១២នេះ។
- ឯកឧត្តម ឡុង រី អ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី ប្រចាំខេត្តក្រចេះ បានរាយការណ៍ថា ផ្លូវមួយខ្សែ និងស្ពានមួយ ដែលត្រូវបានស្នើសុំអំឡុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ខេត្តឆ្នាំ២០១២រួចហើយ។
- ឯកឧត្តម ងួន ស៊ីមអាន តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានរាយការណ៍ថា ប្រឡាយទឹកមួយក្នុងចំណោមប្រឡាយទឹកពីរ ដែលត្រូវបានស្នើសុំដោយអ្នកចូលរួមម្នាក់មកពី ភូមិកំពង់ស្តីលើ ក្នុងខេត្តកំពង់ចាម ត្រូវបានសាងសង់ហើយ។
- នៅក្នុងខេត្តកំពង់ចាម ផ្លូវមួយខ្សែប្រវែង១.៩៧២ម៉ែត្រ ត្រូវបានស្ថាបនាដើម្បីភ្ជាប់ទៅកាន់ឃុំព្រែកតានួង តាមសំណើរបស់អ្នកចូលរួមមកពីភូមិកំពង់រាប។
- នៅក្នុងខេត្តកំពង់ចាម ឃុំកំពង់រាប កំពុងដំណើរការស្ថាបនាប្រឡាយទឹកប្រវែង ៧០០ម៉ែត្រ តាមសំណើរបស់អ្នកចូលរួមមកពីភូមិកំពង់រាប អំឡុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។

- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ឆ្នាំង បានយល់ព្រមស្ថាបនាផ្លូវក្រាលកៅស៊ូមួយខ្សែក្នុងខែមីនា ឆ្នាំ២០១២ តាមសំណើដែលបានលើកឡើងអំឡុងកិច្ចពិភាក្សារវាងអ្នកតំណាង-រាស្ត្រ និងម្ចាស់ឆ្នោត នៅក្នុងខេត្តកំពង់ឆ្នាំង។
- យោងតាមក្រុមប្រឹក្សាឃុំនៅស្រុកកោះសូទិន ខេត្តកំពង់ចាម ផ្លូវមួយខ្សែប្រវែង ១.៩៧២ ម៉ែត្រ ត្រូវបានស្ថាបនាពីភូមិកំពង់ស្ពឺក្រោមឆ្ពោះទៅភូមិកំពង់ស្ពឺកណ្ដាល។
- អភិបាលស្រុកកោះសូទិន ក្នុងខេត្តកំពង់ចាម បានរាយការណ៍ថា មន្ទីរធនធានទឹក កំពុងដំណើរការសាងសង់ប្រឡាយមួយខ្សែប្រវែង ៧០០ម៉ែត្រ។

អ្នកចូលរួមនៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ក៏បានលាតត្រដាងពីសកម្មភាពមិនប្រក្រតី ឬសកម្មភាពខុសច្បាប់ដែលបានកើតឡើងនៅក្នុងសហគមន៍របស់ខ្លួនផងដែរ។ ការលាតត្រដាងនេះ បូករួមជាមួយនឹងអន្តរាគមន៍ជាបន្តបន្ទាប់ពីសំណាក់អ្នកតំណាង-រាស្ត្រផងនោះ បានឈានដល់ការបង្ក្រាបសកម្មភាពដែលកំពុងកើតមាន ហើយវាក៏ជាកត្តាកំញើញអ្នកផ្សេងៗទៀត មិនឲ្យប្រព្រឹត្តខុសផងដែរ។ ឧទាហរណ៍រួមមាន៖

- យោងតាមមេភូមិ និងប្រជាពលរដ្ឋមួយក្រុមក្នុងខេត្តកំពង់ចាម សកម្មភាពក្មេងទំនើងក្នុងភូមិស្វាយទាបបានធ្លាក់ចុះ ដោយសារតែអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋបានសហការគ្នាបង្ក្រាបក្មេងទំនើងទាំងនោះ។
- អ្នកចូលរួមក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ក្រោមការរៀបចំរបស់វិទ្យាស្ថានជាតិ NDI ក្នុងខេត្តកំពង់ឆ្នាំង បានរាយការណ៍ថា ក្រោយបញ្ចប់កិច្ចពិភាក្សា ដែលមានអ្នកចូលរួមត្អូញត្អែរ ពីអំពើពុករលួយដែលកើតមានឡើងនៅមណ្ឌលសុខភាពក្នុងមូលដ្ឋាននោះ បុគ្គលិកពេទ្យនៅមណ្ឌលសុខភាពក្នុងភូមិក្រាំងលាវ បានចាប់ផ្ដើមផ្ដល់សេវាថែទាំសុខភាពដែលមានលក្ខណៈប្រសើរជាងមុន។

## ៥. សេចក្តីសន្និដ្ឋាន

កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ក្រោមការរៀបចំរបស់វិទ្យាស្ថានជាតិ NDI ចាប់ពីខែវិច្ឆិកា ឆ្នាំ២០១១ ដល់ខែកញ្ញា ឆ្នាំ២០១២ បានស្ដែងឲ្យឃើញពីកង្វល់ស្របគ្នាគួរឲ្យកត់សម្គាល់របស់ប្រជាពលរដ្ឋខ្មែរនៅតាមបណ្ដាខេត្តផ្សេងៗ ធៀបទៅនឹងបណ្ដាឆ្នាំមុនៗ។ កង្វល់ទាំងនោះមានជាអាទិ៍ ការពុះពារការពារដីធ្លី អំពើពុករលួយ ការរើសអើង និងភាពក្រីក្រជាដើម។ ទោះជាយ៉ាងណា ជម្លោះដីធ្លី និងអសន្តិសុខទាក់ទងនឹងកម្មសិទ្ធិដីផ្ទាល់ខ្លួន បានគ្របដណ្ដប់កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតខ្លាំងជាងគេ ដោយសំណួរភាគច្រើនលើសលុប គឺពាក់ព័ន្ធនឹងបញ្ហាដីធ្លីនេះតែម្ដង។ ប្រជាពលរដ្ឋកម្ពុជាបានរៀបរាប់ពីអារម្មណ៍របស់ខ្លួនថា សេដ្ឋកិច្ចកម្ពុជា បាននឹងកំពុងរីកចម្រើនក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះក៏ពិតមែន ប៉ុន្តែការអភិវឌ្ឍនេះ បានផ្ដល់ផលប្រយោជន៍ដល់អ្នកមាន អ្នកមានទំនាក់ទំនងនយោបាយ និងជនបរទេសជាងប្រជាពលរដ្ឋសាមញ្ញ។ អារម្មណ៍ខកចិត្ត និងការមិន

ពេញចិត្តនេះ បានស្តែងចេញតាមរយៈការលើកឡើងរបស់ប្រជាពលរដ្ឋ ហើយអ្នកចូលរួមជាច្រើន បាននិយាយឥតលាក់លៀម និងបានសម្តែងការរិះគន់នៅក្នុងវេទិកាទាំងនេះ។



ឯកឧត្តម ទេស ហ៊ាញ អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា និង ឯកឧត្តម សុវណ្ណា ពិសាខា
អ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី ក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត
នៅវត្តមង្គលសួស្តីត្រែង ភូមិក្អាវ ឃុំត្រែង ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង
កាលពីថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១២

អ្នកតំណាងរាស្ត្រ បានសម្តែងអាកប្បកិរិយាប្រកបដោយវិជ្ជាជីវៈ អនុវត្តន៍តាមពិធីការនៃកិច្ចពិភាក្សា និងបញ្ចៀសបាននូវការវាយប្រហារពាក្យសំដីជាលក្ខណៈបុគ្គល និងការរិះគន់បែបបន្ទុះបង្អាប់។ ពួកគេ ក៏បានអនុវត្តន៍តាមវិន័យបក្ស ដោយមិនឆ្លើយចាកប្រធានបទ និងបានបង្ហាញពីគោលជំហរគណបក្សយ៉ាងច្បាស់លាស់ ជាហេតុនាំឲ្យមានការឆ្លើយតបយ៉ាងស៊ីសង្វាក់គ្នាចំពោះបញ្ហាសំខាន់ៗដែលត្រូវបានលើកឡើង។ អ្នកតំណាងរាស្ត្រ បានបង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការស្តាប់ម្ចាស់ឆ្នោត ហើយបានឆ្លើយតបយ៉ាងច្បាស់ៗចំពោះកង្វល់របស់ពួកគេ។ កម្រិតជំនាញមានលក្ខណៈខុសៗគ្នាក្នុងចំណោមអ្នកតំណាងរាស្ត្រម្នាក់ៗ ប៉ុន្តែសកម្មភាពរបស់ពួកគេមិនជាប់ទាក់ទិនជាមួយនិន្នាការគណបក្សទេ។ អ្នកចូលរួមហាក់ដូចជា បានបញ្ចេញប្រតិកម្មវិជ្ជមានចំពោះអ្នកតំណាងរាស្ត្រ ដែលបានឆ្លើយតបជាក់លាក់ និងមានលក្ខណៈជាប្រព័ន្ធ ចំពោះបញ្ហានីមួយៗដែលត្រូវបានលើកឡើង ជាងអ្នកដែលនិយាយមិនចំប្រធានបទ ឬឲ្យមន្ត្រីមូលដ្ឋានឆ្លើយតបជំនួសខ្លួន។

នៅក្នុងករណីមួយចំនួន គណបក្សនយោបាយ បានបញ្ជូនអ្នកតំណាងរាស្ត្រពីមណ្ឌលផ្សេងឲ្យមកចូលរួមក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ឬបញ្ជូនសមាជិក

ព្រឹទ្ធសភា ដែលមិនបានទទួលការបោះឆ្នោតជ្រើសរើសដោយផ្ទាល់ពីប្រជាពលរដ្ឋ ហើយបញ្ហានេះបានកើតមានជាញឹកញាប់ក្នុងឆ្នាំ២០១២នេះ។

| ឈ្មោះអ្នកតំណាងរាស្ត្រ | មណ្ឌល | ចូលរួមក្នុងកិច្ចពិភាក្សារវាងអ្នកតំណាង-រាស្ត្រ និងម្ចាស់ឆ្នោតនៅក្នុងខេត្ត |
|---|---|---|
| **គណបក្សសិទ្ធិមនុស្ស (HRP)** | | |
| ឯកឧត្តម យ៉ែម បុញ្ញឫទ្ធិ | ព្រៃវែង | កំពង់ចាម |
| ឯកឧត្តម អ៊ូ ច័ន្ទឫទ្ធិ | កណ្ដាល | កំពង់ចាម |
| **គណបក្ស សម រង្ស៊ី (SRP)** | | |
| ឯកឧត្តម សាន សាង | តាកែវ | កំពង់ចាម |
| ឯកឧត្តម ជាម ច័ន្ទនី | កំពង់ចាម | កំពង់ឆ្នាំង |
| ឯកឧត្តម គួយ ប៊ុនរឿន | តាកែវ | កំពង់ចាម |
| ឯកឧត្តម គីមសួរ ភិរិទ្ធ | កំពង់ចាម | កំពង់ឆ្នាំង |
| ឯកឧត្តម សុវណ្ណា ពិសាខា | កំពង់ចាម | បាត់ដំបង |
| **គណបក្សប្រជាជនកម្ពុជា (CPP)** | | |
| ឯកឧត្តម អាំ សំអាត សមាជិកព្រឹទ្ធសភា | សៀមរាប | សៀមរាប |

អ្នកតំណាងរាស្ត្រ ត្រូវបានគេបោះឆ្នោតជ្រើសរើសតាមមណ្ឌល ដែលមានឈ្មោះរបស់ខ្លួនក្នុងបញ្ជីឈ្មោះបេក្ខជនតាមខេត្ត ហើយពួកគេត្រូវទទួលខុសត្រូវចំពោះម្ចាស់ឆ្នោតនៅក្នុងខេត្តនោះតែម្ដង។ នៅពេលដែលអ្នកតំណាងរាស្ត្រមកពីមណ្ឌលផ្សេង ចូលរួមក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ជារឿយៗ ពួកគេធ្វើមិនបានល្អដូចអ្នកតំណាងរាស្ត្រមកពីមណ្ឌលនោះផ្ទាល់ទេ ពីព្រោះពួកគេ មិនសូវដឹងច្បាស់អំពីបញ្ហានៅក្នុងមូលដ្ឋាន និងមិនសូវស្គាល់ថ្នាក់ដឹកនាំមូលដ្ឋាន ដូច្នេះពុំមានលទ្ធភាពក្នុងការតាមដានឲ្យបានជិតដល់ឡើយ។ អ្នកចូលរួមស្ដាប់នៅក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ហាក់ដូចជាមានអារម្មណ៍ច្របូកច្របល់ជាពិសេស នៅពេលដែលអ្នកតំណាងរាស្ត្រមកពីមណ្ឌលផ្សេង ថ្លែងអំណរអរគុណពួកគាត់ដែលបានបោះឆ្នោតឲ្យ។ តាមច្បាប់រដ្ឋធម្មនុញ្ញ សមាជិកសភាមានភារកិច្ចធ្វើជាតំណាងឲ្យប្រជាពលរដ្ឋទាំងអស់ក៏ពិតមែន ប៉ុន្តែគណបក្ស និងអ្នកតំណាងរាស្ត្រនានា គួរតែផ្ដោតការយកចិត្តទុកដាក់ដោយផ្ទាល់លើអ្នកបោះឆ្នោតក្នុងមណ្ឌលរបស់ខ្លួន ព្រោះនេះជាយុទ្ធសាស្ត្រមួយដែលអាចជួយឲ្យខ្លួនជាប់ឆ្នោតម្ដងទៀតនាពេលអនាគតក្នុងមណ្ឌលនោះ។ វាប្រសើរជាងការបញ្ជូនអ្នកតំណាងរាស្ត្រចុះជួបប្រជាពលរដ្ឋទូទាំងប្រទេស។

កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត បានផ្ដល់លទ្ធផលជាក់ច្បាស់មួយចំនួនដោយលទ្ធផលជាច្រើនអាចសន្និដ្ឋានបានថា បណ្ដាលមកពីសកម្មភាពរបស់អ្នកតំណាងរាស្ត្រ ដែលបានចូលរួមក្នុងកិច្ចពិភាក្សាទាំងនោះ។ អ្នកតំណាងរាស្ត្រ បានបង្ហាញពីការប្ដេជ្ញាចិត្តយ៉ាងមុតមាំចំពោះម្ចាស់ឆ្នោត និងបានបង្ហាញនូវភារកិច្ចជាអ្នកតំណាងឲ្យប្រជាពលរដ្ឋ ហើយអ្នកតំណាងរាស្ត្រជាច្រើន បានគោរពតាមការសន្យារបស់ខ្លួនយ៉ាងតិចក៏មួយដែរ។ អន្តរាគមន៍ផ្សេងៗទៀត

ត្រូវបានដឹកនាំដោយសហគមន៍ ឬអាជ្ញាធរមូលដ្ឋាន។ នៅក្នុងករណីជាច្រើន អ្នកតំណាងរាស្ត្រ បានចាត់វិធានការ ដូចជា តាមរយៈការសរសេរលិខិតផ្ញើជូនរដ្ឋមន្ត្រី ឬពិគ្រោះយោបល់ជាមួយ អភិបាលខេត្តដើម្បីដោះស្រាយបញ្ហាណាមួយ។ វិធានការទាំងអស់ មិនមែនសុទ្ធតែទទួលបាន លទ្ធផលជាក់ស្តែងនោះទេ តែទោះជាយ៉ាងណា វិទ្យាស្ថានជាតិ NDI ទទួលស្គាល់ការប្រឹងប្រែង របស់អ្នកតំណាងរាស្ត្រទាំងអស់ ក្នុងការឆ្លើយតបចំពោះកង្វល់នានាដែលម្ចាស់ឆ្នោតរបស់ខ្លួន បានលើកឡើង។

តាមរយៈសកម្មភាពទាំងអស់នេះ មុខងារតំណាងរបស់សមាជិកសភា ត្រូវបានពង្រឹង ដោយសារពួកគេ បានពាំនាំកង្វល់របស់ម្ចាស់ឆ្នោត ជូនស្ថាប័នពាក់ព័ន្ធដោះស្រាយ។ ដូចដែល អ្នកតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជាម្នាក់ បានលើកឡើងក្នុងសិក្ខាសាលាវាយតម្លៃ លទ្ធផលនៃកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតថា "កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនេះ បានផ្លាស់ប្តូរអាកប្បកិរិយា និងការឆ្លើយតបរបស់អ្នកតំណាងរាស្ត្រ"។ អ្នកតំណាងរាស្ត្រ ក៏បានធ្វើការពិនិត្យតាមដានជាប្រចាំផងដែរ ជាពិសេសទាក់ទងនឹងការអនុវត្ត ខុសច្បាប់នៅថ្នាក់មូលដ្ឋាន។ ប៉ុន្តែ មានការកត់សម្គាល់ផងដែរថា គ្មានការអន្តរាគមន៍ណាមួយ ពាក់ព័ន្ធដល់ស្ថាប័ននីតិប្បញ្ញត្តិទេ។ ផ្ទុយទៅវិញ បញ្ហាទាំងនោះត្រូវបានដោះស្រាយតាមរយៈ ការិយាល័យ និងក្រសួងពាក់ព័ន្ធ។ ទោះជាបញ្ហាជាច្រើនដែលត្រូវបានលើកឡើងអំឡុង កិច្ចពិភាក្សានេះ ស្ថិតក្នុងយុត្តាធិការរបស់ស្ថាប័ននីតិប្រតិបត្តិក៏ពិតមែន ប៉ុន្តែរដ្ឋសភាជាតិអាចដើរ តួនាទីដ៏សំខាន់មួយក្នុងការដោះស្រាយបញ្ហានានា តាមរយៈមុខងារតាក់តែងច្បាប់របស់ខ្លួនដែរ។ ប្រជាពលរដ្ឋ បានឆ្លើយយ៉ាងត្រឹមត្រូវអំពីមុខងារតាក់តែងច្បាប់របស់សភាជាតិ ដែលមិនមែន គ្រាន់តែចាំអនុម័តសេចក្តីព្រាងច្បាប់របស់រដ្ឋាភិបាល និងបានសម្តែងនូវក្តីរំពឹងថា សភាជាតិ នឹង បន្តអនុវត្តអំណាចនេះជាមិនខាន។

កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការ បង្ហាញជូនប្រជាពលរដ្ឋទូទាំងប្រទេសនូវជម្រើសនយោបាយរបស់ខ្លួន។ នៅកម្ពុជា មានឱកាស តិចតួចណាស់ ដែលអ្នកតំណាងរាស្ត្រគណបក្សកាន់អំណាច និងគណបក្សប្រឆាំងបានចូលរួម ជាមួយគ្នាក្នុងវេទិកាសាធារណៈ ដើម្បីឆ្លើយសំណួរប្រជាពលរដ្ឋ។ លើសពីនេះទៅទៀត កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត បានលើកទឹកចិត្តអ្នកតំណាងរាស្ត្រឲ្យធ្វើការមិន ប្រកាន់និន្នាការនយោបាយ នៅក្នុងករណីមួយចំនួនតូច។ ដូចដែលអ្នកតំណាងរាស្ត្រគណបក្ស ប្រជាជនកម្ពុជាម្នាក់បានលើកឡើង ក្នុងកិច្ចប្រជុំវាយតម្លៃលទ្ធផលនៃកម្មវិធីកិច្ចពិភាក្សារវាង អ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតថា "មានតែនៅក្នុងកម្មវិធីនៃកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតទេ ទើបអ្នកតំណាងរាស្ត្រ មានឱកាសធ្វើការរួមគ្នាដើម្បីជួយប្រជាជនបាន"។ កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនេះ ក៏បាននាំមកនូវឱកាសពិសេសមួយសម្រាប់ ប្រជាពលរដ្ឋក្នុងការបញ្ចេញទស្សនៈរបស់ខ្លួនក្នុងបរិយាកាសអព្យាក្រឹតផងដែរ។ ដូចដែល អ្នកតំណាងរាស្ត្រមកពីគណបក្ស សម រង្ស៊ី មួយរូប បានធ្វើការកត់សម្គាល់ថា "បញ្ហាប្រឈមចំពោះ ប្រជាពលរដ្ឋកម្ពុជា គឺការបញ្ចេញទស្សនៈរបស់ខ្លួនជាសាធារណៈ។ កិច្ចពិភាក្សារវាងអ្នកតំណាង-

រាស្ត្រ និងម្ចាស់ឆ្នោត ផ្តល់នូវឱកាសដ៏កម្រនេះ។ កិច្ចពិភាក្សានេះ ជួយពង្រឹងលទ្ធិប្រជាធិបតេយ្យ និងសេរីភាពក្នុងការបញ្ចេញមតិ។ សង្គមខ្មែរត្រូវការប្រជាធិបតេយ្យ និងសេរីភាពនេះជាទីបំផុត"។

ទោះបីជាកិច្ចពិភាក្សានេះ បានផ្តល់ផលប្រយោជន៍ទាំងនេះហើយក៏ដោយចុះ ការប្រជុំក្រុមគោលដៅបានបង្ហាញថា ប្រជាពលរដ្ឋ នៅតែមានការយល់ដឹងមានកម្រិតនៅឡើយអំពីរដ្ឋសភា និងគោលបំណងរបស់រដ្ឋសភា។ ជាញឹកញាប់ អ្នកចូលរួមដឹងត្រឹមតែថា ការតាក់តែងច្បាប់គឺជាតួនាទីចម្បងរបស់រដ្ឋសភា ហើយបានបង្ហាញការយល់ដឹងតិចតួចណាស់អំពីផលប៉ះពាល់របស់ច្បាប់នីមួយៗ។ ប្រជាពលរដ្ឋ យល់មិនច្បាស់អំពីតួនាទីរបស់អ្នកតំណាងរាស្ត្រម្នាក់ៗទេ និងបានយល់ច្រឡំថា អ្នកតំណាងរាស្ត្រមានតួនាទីចែកអំណោយ និងផ្តល់សេវានានាជូនប្រជាពលរដ្ឋដូចរាជរដ្ឋាភិបាលដែរ។ ទោះបីជាការចូលរួមក្នុងកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត បានជួយពង្រឹងការយល់ដឹងរបស់ពួកគេក៏ដោយ ក៏អ្នកចូលរួមនៅតែយល់មិនបានទូលំទូលាយអំពីតួនាទីរបស់រដ្ឋសភា និងអ្នកតំណាងរាស្ត្រ ឬការផ្សារភ្ជាប់រវាងស្ថាប័ននីតិប្បញ្ញត្តិ និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួន។ វាទំនងជាក្នុងទិដ្ឋភាពជាក់ស្តែង ដែលថា រដ្ឋសភា និងអ្នកតំណាងរាស្ត្រ មានឥទ្ធិពលតិចតួចមកលើពួកគេរហូតពេលនេះ។ ប្រជាពលរដ្ឋមួយចំនួនតូចធ្លាប់មានទំនាក់ទំនងជាមួយ ឬធ្លាប់ទទួលបានព័ត៌មានពីរដ្ឋសភា និងអ្នកតំណាងរាស្ត្រ មុនកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត។ អ្នកចូលរួមក្នុងកិច្ចពិភាក្សាក្រុមគោលដៅភាគច្រើន មិនស្គាល់ឈ្មោះច្បាប់សូម្បីតែមួយ មិនដឹងអំពីគំនិតផ្តួចផ្តើម ឬកម្មវិធីផ្សេងៗ ដូចជាការរៀបចំដំណើរទស្សនកិច្ចជាសាធារណៈទៅកាន់សភាជាតិ វេទិការៀបចំផ្សព្វផ្សាយ វេទិកាមហាជន (public hearing) សន្និសីទ ឬកម្មវិធីផ្តល់ព័ត៌មាន ដែលរៀបចំឡើងដោយស្ថាប័ននីតិប្បញ្ញត្តិតាងនាមឲ្យប្រជាពលរដ្ឋឡើយ។

លទ្ធផលទាំងនេះបង្ហាញថា រដ្ឋសភា និងអ្នកតំណាងរាស្ត្របំពេញភារកិច្ចរបស់ខ្លួនមិនទាន់បានល្អទេ ពីព្រោះប្រជាពលរដ្ឋនៅតែមិនសូវយល់ពីការងាររបស់រដ្ឋសភា និងរបស់អ្នកតំណាងរាស្ត្រឡើយ។ ក្រៅពីមិនបានផ្តួចផ្តើមគំនិតលើការតាក់តែងច្បាប់ហើយនោះរដ្ឋសភាពុំមានដំណើរការរៀបចំវេទិកាមហាជន ឬការសិក្សាស្រាវជ្រាវ និងការស៊ើបអង្កេតឲ្យបានស៊ីជម្រៅទេ។ រដ្ឋសភា មិនបានសម្របសម្រួលកិច្ចប្រឹងប្រែងឲ្យបានគ្រប់គ្រាន់ក្នុងការចុះតាមមណ្ឌល ឬមធ្យោបាយផ្សេងៗ ក្នុងការផ្សព្វផ្សាយព័ត៌មាន ឧទាហរណ៍ ដូចជាតាមរយៈព្រឹត្តិប័ត្រ អ៊ីម៉ែល ឬប្រព័ន្ធផ្សព្វផ្សាយព័ត៌មានៗផ្សេងទៀតឡើយ។ ស្ថាប័ននីតិប្រតិបត្តិ បែរជាដើរតួជាអ្នកកំណត់របៀបវារៈរដ្ឋសភា និងដឹកនាំរដ្ឋសភាលើគ្រប់កិច្ចការរបស់ស្ថាប័ននេះទៅវិញ។ ទោះជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋកម្ពុជា នៅតែចាប់អារម្មណ៍ចំពោះការស្តាប់អ្នកតំណាងរាស្ត្ររបស់ខ្លួនព្រមទាំងមានជំនឿទុកចិត្តថា អ្នកតំណាងរាស្ត្រ នឹងបំពេញតាមការសន្យារបស់ខ្លួន។ ម្ចាស់ឆ្នោតចង់បង្កើនការទំនាក់ទំនង ក៏ដូចជាការទទួលបានព័ត៌មានពីអ្នកដែលខ្លួនបានបោះឆ្នោតជ្រើសរើសឲ្យបម្រើផលប្រយោជន៍ពួកគាត់នៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ។

កម្មវិធីទំនាក់ទំនងរវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតរបស់វិទ្យាស្ថានជាតិ NDI បានផ្តល់ឱកាសដ៏មានសារៈសំខាន់សម្រាប់អ្នកតំណាងរាស្ត្រ ក្នុងការកសាងទំនាក់ទំនងជាមួយ

សហគមន៍ និងក្នុងការបំពេញភារកិច្ចរបស់ខ្លួន។ ដូចដែលអ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី បានលើកឡើងនៅក្នុងសិក្ខាសាលាវាយតម្លៃលទ្ធផលនៃកម្មវិធីកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតថា "កិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ជួយធ្វើឲ្យប្រាកដថា ប្រជាពលរដ្ឋស្គាល់អ្នកតំណាងរបស់ខ្លួន និងផ្តល់ឱកាសឲ្យអ្នកតំណាងរបស់ខ្លួនដោះស្រាយបញ្ហារបស់ពួកគាត់"។ ទោះជាយ៉ាងណា ការមានកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនេះ នៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ រដ្ឋសភា និងសមាជិកសភា គួរតែផ្តល់ព័ត៌មានឲ្យបានកាន់តែច្រើនដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានអំពីការងារ របៀបវារៈ និងកម្មវិធីរបស់រដ្ឋសភា និងផ្តល់លទ្ធភាពឲ្យសមាជិកសភាគ្រប់រូបបង្កើនកិច្ចប្រឹងប្រែង ក្នុងការចុះសួរសុខទុក្ខម្ចាស់ឆ្នោតរបស់ខ្លួនឲ្យបានកាន់តែញឹកញាប់។

## ឧបសម្ព័ន្ធ

## តារាងសង្ខេបអំពីព្រឹត្តិការណ៍នៃកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោតរបស់វិទ្យាស្ថានជាតិ NDI
## ពីខែវិច្ឆិកា ឆ្នាំ២០១១ ដល់ខែកញ្ញា ឆ្នាំ២០១២

| កាលបរិច្ឆេទ | ទីតាំងនៃកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត | | | | អ្នកចូលរួម | | | អ្នកតំណាងរាស្ត្រ | |
|---|---|---|---|---|---|---|---|---|---|
| | ខេត្ត | ស្រុក | ឃុំ | ភូមិ | ប្រុស | ស្រី | សរុប | ឈ្មោះ | គណបក្ស |
| ១៩/១១/២០១១ | ក្រចេះ | ចិត្របុរី | ថ្មអណ្ដើក | ជួរក្រូច | ២១៥ | ១៧៤ | **៣៨៩** | លោកជំទាវ ត្រឹង ថាវី | CPP |
| | | | | | | | | ឯកឧត្តម ឡុង រី | SRP |
| ២៦/១១/២០១១ | កំពង់ចាម | ចំការលើ | តាប្រុក | រំចេក | ៣៤៥ | ៣០៦ | **៦៥១** | លោកជំទាវ ចែម សាវ៉ៃ | CPP |
| | | | | | | | | ឯកឧត្តម សាន សាង | SRP |
| | | | | | | | | ឯកឧត្តម យ៉ែម បុញ្ញឫទ្ធិ | HRP |
| | | | | | | | | ឯកឧត្តម យូ ហុកគ្រី | NRP |
| ១៧/១២/២០១១ | កំពង់ឆ្នាំង | កំពង់ត្រឡាច | តាជេស | ឡពាង | ១៩៤ | ៦១ | **២៥៥** | លោកជំទាវ កែ ច័ន្ទមុនី | CPP |
| | | | | | | | | ឯកឧត្តម ជាម ច័ន្ទនី | SRP |
| ១៤/០១/២០១២ | កំពង់ចាម | កោះសូទិន | កំពង់រាប | កំពង់ស្ដីក្រោម | ៣៦១ | ២១០ | **៥៧១** | ឯកឧត្តម ងួន ស៊ឹមអាន | CPP |
| | | | | | | | | ឯកឧត្តម គួយ ប៊ុនរឿន | SRP |
| | | | | | | | | ឯកឧត្តម កឹម សុខា | HRP |
| | | | | | | | | ឯកឧត្តម យូ ហុកគ្រី | NRP |
| ២១/០១/២០១២ | ក្រចេះ | ក្រចេះ | អូរឫស្សី | ស្រែស្ដៅ | ២៤៧ | ១៥៣ | **៤០០** | ឯកឧត្តម កាទើ តូយ៉េប | CPP |
| | | | | | | | | ឯកឧត្តម ឡុង រី | SRP |
| ១០/០៣/២០១២ | កំពង់ឆ្នាំង | រលាប្អៀរ | ក្រាំងលាវ | ក្រាំងលាវ | ១៩៧ | ៨១ | **២៧៨** | លោកជំទាវ កែ ច័ន្ទមុនី | CPP |
| | | | | | | | | ឯកឧត្តម គីមសួរ ភិរិទ្ធ | SRP |
| ៣០/០៦/២០១១ | បាត់ដំបង | រតនៈមណ្ឌល | ត្រែង | ភ្លាវ | ៤៥៥ | ៣១០ | **៧៦៥** | ឯកឧត្តម ទេស ហ៊ាញ | CPP |
| | | | | | | | | ឯកឧត្តម សុវណ្ណា ពិសាខា | SRP |

| កាលបរិច្ឆេទ | ទីតាំងនៃកិច្ចពិភាក្សារវាងអ្នកតំណាងរាស្ត្រ និងម្ចាស់ឆ្នោត | | | | អ្នកចូលរួម | | | អ្នកតំណាងរាស្ត្រ | |
|---|---|---|---|---|---|---|---|---|---|
| | ខេត្ត | ស្រុក | ឃុំ | ភូមិ | ប្រុស | ស្រី | សរុប | ឈ្មោះ | គណបក្ស |
| ០៧/០៧/២០១២ | កណ្ដាល | ខ្សាច់កណ្ដាល | វិហារសួគ៌ | វិហារសួគ៌ជើង | ៣៧៣ | ២៦៨ | ៦៤១ | ឯកឧត្តម អ៊ុក ដាមរី | CPP |
| | | | | | | | | ឯកឧត្តម ឃឹម ឡាគី | SRP |
| | | | | | | | | ឯកឧត្តម អ៊ូ ច័ន្ទឫទ្ធិ | HRP |
| ១៤/០៧/២០១២ | កំពង់ចាម | ស្រីសន្ធរ | ព្រែករំដេង | ត្នោតក | ៤៥០ | ៣៤៣ | ៧៩៣ | ឯកឧត្តម វ៉ាន់ សេងលី | CPP |
| | | | | | | | | ឯកឧត្តម សាន សាង | SRP |
| | | | | | | | | ឯកឧត្តម អ៊ូ ច័ន្ទឫទ្ធិ | HRP |
| ២១/០៧/២០១២ | ក្រចេះ | ឆ្លូង | ព្រែក សាម៉ាន់ | ព្រែកសាម៉ាន់ | ២៨៨ | ២៤០ | ៥២៨ | លោកជំទាវ ត្រឹង ថារី | CPP |
| | | | | | | | | ឯកឧត្តម ឡុង រី | SRP |
| ២៨/០៧/២០១២ | សៀមរាប | អង្គរធំ | លាងដៃ | លាងដៃ | ១៧៩ | ២៤៦ | ៤២៥ | ឯកឧត្តម អាំ សំអាត | CPP |
| | | | | | | | | ឯកឧត្តម គី វ៉ាន់ដារ៉ា | SRP |
| ១១/០៨/២០១២ | កំពង់ឆ្នាំង | ទឹកផុស | ក្បាលទឹក | ក្រសាំងដុះឡើង | ៣៥២ | ៣៦៨ | ៧២០ | លោកជំទាវ កែ ច័ន្ទមុនី | CPP |
| | | | | | | | | ឯកឧត្តម ជាម ច័ន្ទនី | SRP |
| ១៨/០៨/២០១២ | កំពង់ស្ពឺ | ភ្នំស្រួច | តាំងសំរោង | ក្រាំងបឹង | ២៩៣ | ១៨២ | ៤៧៥ | ឯកឧត្តម លី សុន | CPP |
| | | | | | | | | ឯកឧត្តម សុខ អ៊ុំស៊ា | SRP |
| ០១/០៩/២០១២ | កំពង់ធំ | សន្ទុក | កកោះ | ស្វាយកាល់ | ៣៦០ | ១៨៥ | ៥៤៥ | ឯកឧត្តម ស៊ិក ប៊ុនហុក | CPP |
| | | | | | | | | ឯកឧត្តម កែត ឃី | SRP |
| សរុប | | | | | ៤.៣០៩ | ៣.១២៥ | ៧.៤៣៦ | | |